# ការកំណត់ស្តង់ដារ និយមន័យអ្នកទទួលផលក្នុងសកម្មភាពកម្ចាត់មីនមនុស្សធម៌

បោះពុម្ពលើកទីពីរ





# បោះពុម្ពលើកទីពីរ
# ខែតុលា ឆ្នាំ២០២០

ការបោះពុម្ពលើកទីពីរនៃឯកសារនេះគឺផ្អែកលើការពង្រីកក្រុមការងារបច្ចេកទេស ដែលរួមមាន អង្គការជំនួយព្រះវិហារដាណឺម៉ាក (DCA) អង្គការ Danish Demining Group (DDG) អង្គការហេឡូត្រាស្ត (HALO) អង្គការ Humanity & Inclusion (HI) អង្គការ ម៉ែក (MAG) អង្គការជំនួយនៃប្រជាពលរដ្ឋន័រវេស្សន៍ (NPA) និងមូលនិធិស្វីសសម្រាប់ការដោះមីន (FSD)។ ការពិគ្រោះយោបល់ផ្សេងទៀតត្រូវបានធ្វើឡើងជាមួយមជ្ឈមណ្ឌលអន្តរជាតិទីក្រុងហ្សឺណែវសម្រាប់បោសសម្អាតមីនមនុស្សធម៌ (GICHD) គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) និងស្ថាប័នអង្គការសហប្រជាជាតិ រួមមាន សេវាកម្មសកម្មភាពកម្ចាត់មីនរបស់អង្គការសហប្រជាជាតិ (UNMAS) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF)។ ឯកសារនេះអាចត្រូវបានចែករំលែកដរាបណាមានការយោងដោយសមស្រប។

**រូបភាពក្របឯកសារ៖** ភូមិ Kanenguerere នៅក្នុងប្រទេសអង់ហ្គោឡាដែលត្រូវបានព័ទ្ធដោយចម្ការមីនចំនួនប្រាំ រហូតដល់ការងារបោសសម្អាតមីនបានចាប់ផ្តើមដើម្បីធ្វើឲ្យដីមានសុវត្ថិភាព។ © Scout Tufankjian/អង្គការ HALO Trust

**រូបភាពខាងលើ៖** កសិករម្នាក់បង្ហាញផ្លែស្វាយដែលគាត់ទើបបេះពីចម្ការរបស់គាត់ដែលពីមុនមានបញ្ហាយុទ្ធភ័ណ្ឌជាតិផ្ទុះ។ El Orejon តំបន់ Antioquia ប្រទេសកូឡុំប៊ី។ © Giovanni Fiffidenti/អង្គការ NPA

# តារាងមាតិកា


សទ្ទានុក្រម និងអក្សរកាត់ ..... 4

បុព្វកថា ..... 6

គោលបំណង ..... 6

គោលការណ៍ ..... 8

- ការប្រមូលទិន្នន័យពាក់ព័ន្ធនឹងជនមានពិការភាព ..... 9

ការអប់រំពីហានិភ័យនៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ..... 11

- ការកំណត់អ្នកទទួលផល ..... 11
- គោលការណ៍ណែនាំស្តីពីការវាស់វែង និងការរាយការណ៍ពីអ្នកទទួលផល EORE ..... 12

ការរំដោះផ្ទៃដី ..... 13

- ការកំណត់អ្នកទទួលផល ..... 13
- ប្រភេទនៃការប្រើប្រាស់ដី និង និយមន័យអ្នកទទួលផលផ្ទាល់ ..... 16
- គោលការណ៍ណែនាំស្តីពីការវាស់វែង និងរាយការណ៍ពីអ្នកទទួលផលពីការរំដោះផ្ទៃដី ..... 17

កិច្ចជួយសង្គ្រោះជនរងគ្រោះ ..... 20

- ការកំណត់អ្នកទទួលផល ..... 20
- គោលការណ៍ណែនាំស្តីពីការវាស់វែង និងការរាយការណ៍ពីអ្នកទទួលផល VA ..... 21

ការកម្ទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ..... 23

- ការកំណត់អ្នកទទួលផល ..... 23
- គោលការណ៍ណែនាំទៅលើការវាស់វែង និងការរាយការណ៍ពីអ្នកទទួលផល EOD ..... 24

# សន្ទានុក្រម និងអក្សរកាត់

| | |
|---|---|
| លប់ចោលតំបន់សង្ស័យ | តំបន់ដែលបានកំណត់ហើយ<br>ត្រូវបានសន្និដ្ឋានថាមិនមានភស្តុតាងបញ្ហាជាតិផ្ទុះបន្ទាប់ពីធ្វើការស្រាវជ្រាវមិនបច្ចេកទេសលើ |
| ការបោសសម្អាត | នៅក្នុងបរិបទនៃសកម្មភាព**កម្ចាត់**មីន ពាក្យនេះសំដៅទៅលើកិច្ចការ ឬសកម្មភាពដើម្បីធានា**នូវ**ការយកចេញនិង / ឬការ**កំទេចគ្រឿង**យុទ្ធភ័ណ្ឌជាតិផ្ទុះពីតំបន់ដែលបានបញ្ជាក់ ជម្រៅដែលបានបញ្ជាក់ ឬប៉ារ៉ាម៉ែត្រដែលបានព្រមព្រៀងផ្សេងទៀតដូចដែលបានចែងដោយ NMAA/អាជ្ញាធរដែលមានសិទ្ធិអំណាច។ |
| **យុទ្ធភ័ណ្ឌជាតិផ្ទុះ**<br>**( EO )** | អាវុធជាតិផ្ទុះណាមួយខាងក្រោមដែលតម្រូវឲ្យមានការឆ្លើយតបសកម្មភាព**កម្ចាត់**មីន ៖<br>• គ្រាប់មីន<br>• គ្រាប់បែកចង្កោម<br>• យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ<br>• យុទ្ធភ័ណ្ឌដែលត្រូវបានគេបោះបង់ចោល<br>• ខ្សែមីនអន្ទាក់<br>• ឧបករណ៍ផ្សេងៗ ( ដូចបានកំណត់ដោយ CCW APII )<br>• ឧបករណ៍ជាតិផ្ទុះកែច្នៃ[1] |
| **ការកម្ទេចយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ( EOD )** | ការរកឃើញ ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ ការបង្ហាញថាមានសុវត្ថិភាព ការទាញយក និងការបំផ្លាញចោលនៃ EO។ **ការកម្ទេចយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ**អាចត្រូវបានអនុវត្ត៖<br>ក ) ជាផ្នែកដដែលៗនៃប្រតិបត្តិការបោសសម្អាតមីន នៅពេលរកឃើញយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ<br>ខ ) ដើម្បីបំផ្លាញសំណល់ជាតិផ្ទុះពីសង្គ្រាមដែលត្រូវបានរកឃើញនៅខាងក្រៅតំបន់ដែលមានគ្រោះថ្នាក់ (វាប្រហែលជាវត្ថុតែមួយនៃសំណល់ជាតិផ្ទុះពីសង្គ្រាម ឬចំនួនច្រើននៅក្នុងតំបន់ជាក់លាក់មួយ ) ឬ<br>គ ) ដើម្បីបំផ្លាញ EO ដែលបានក្លាយជាគ្រោះថ្នាក់ដោយការខូចគុណភាព ការខូចខាត ឬការប៉ុនប៉ងបំផ្លាញ។ |
| **ការអប់រំហានិភ័យយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ( EORE )** | សកម្មភាពដែលព្យាយាមកាត់បន្ថយហានិភ័យគ្រោះថ្នាក់ដោយសារគ្រាប់មីន ឬសំណល់ជាតិផ្ទុះពីសង្គ្រាម ដោយការលើកកម្ពស់ការយល់ដឹងរបស់បុរស ស្ត្រី និងកុមារ ដោយអនុលោមទៅតាមភាពងាយរងគ្រោះ តួនាទីនិងតម្រូវការផ្សេងៗគ្នា និងលើកកម្ពស់ការផ្លាស់ប្តូរអាកប្បកិរិយា រួមមានការផ្សព្វផ្សាយព័ត៌មានសាធារណៈ ការអប់រំនិងបណ្តុះបណ្តាល និងទំនាក់ទំនងសកម្មភាពកម្ចាត់មីននៅតាមសហគមន៍។ |
| **សម្ភារព័ត៌មាន អប់រំ និងទំនាក់ទំនង ( IEC )** | សម្ភារ ដូចជា**ប័ណ្ណ**ប្រកាស ផ្ទាំងផ្សព្វផ្សាយ ផ្ទាំងគំនូរលើជញ្ជាំង **ខិត្តប័ណ្ណ ស្ទីកគ័រ** -ល- **ដែល**ត្រូវ**បាន**ប្រើប្រាស់សម្រាប់ព័ត៌មាន ការអប់រំ និងទំនាក់ទំនង |
| **ស្តង់ដារសកម្មភាពកម្ចាត់មីនអន្តរជាតិ ( IMAS )** | ស្តង់ដារសកម្មភាពកម្ចាត់មីនអន្តរជាតិ ( IMAS ) គឺជាស្តង់ដារជាធរមានសម្រាប់ប្រតិបត្តិការសកម្មភាពកម្ចាត់មីនទាំងអស់។ **វា** **ជា**ការកំណត់ស្តង់ដារសម្រាប់ប្រតិបត្តិការមូលដ្ឋាននៅទូទាំងពិភពលោក **ដោយ**ក្រុមខណ្ឌ IMAS**បាន** |
| **ប្រព័ន្ធគ្រប់គ្រងទិន្នន័យសកម្មភាពមីន ( IMSMA )** | ប្រព័ន្ធព័ត៌មានដែលអង្គការសហប្រជាជាតិចូលចិត្តប្រើសម្រាប់ការគ្រប់គ្រងទិន្នន័យសំខាន់ៗនៅក្នុងកម្មវិធីតាមមូលដ្ឋានដែលគាំទ្រដោយអង្គការសហប្រជាជាតិ។ IMSMA ផ្តល់ជូនអ្នកប្រើប្រាស់នូវការគាំទ្រសម្រាប់ការប្រមូលទិន្នន័យ ការផ្ទុកទិន្នន័យ ការរាយការណ៍ ការវិភាគព័ត៌មាន និងសកម្មភាពគ្រប់គ្រងគម្រោង។ ការប្រើប្រាស់បឋមរបស់វាគឺត្រូវបានប្រើដោយបុគ្គលិក នៃ MACs នៅថ្នាក់ជាតិនិងថ្នាក់តំបន់ ទោះយ៉ាងណាប្រព័ន្ធនេះក៏ត្រូវបានដាក់ប្រើដើម្បីគាំទ្រដល់អ្នកអនុវត្តគម្រោងសកម្មភាពកម្ចាត់មីន និងអង្គការដោះមីនគ្រប់កម្រិត។ |
| **ការរំដោះផ្ទៃដី** | នៅក្នុងបរិបទនៃសកម្មភាពកម្ចាត់មីន ពាក្យនេះពិពណ៌នាអំពីដំណើរការនៃការអនុវត្ត "ការខិតខំដោយសមហេតុផលទាំងអស់" ដើម្បីកំណត់អត្តសញ្ញាណ កំណត់និងយកចេញនូវរាល់វត្តមាន និងការសង្ស័យនៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និង/ឬការបោសសម្អាត។ លក្ខណៈវិនិច្ឆ័យសម្រាប់ "កិច្ចខិតខំដោយប្រឹងប្រែងសមហេតុផលទាំងអស់" |
| **អាជ្ញាធរជាតិសកម្មភាពកម្ចាត់មីន ( NMAA )** | អង្គភាពរដ្ឋាភិបាល ដែល**ធម្មតា**ជាគណៈកម្មាធិការអន្តរក្រសួងក្នុងប្រទេសដែលរងផលប៉ះពាល់ដោយគ្រាប់មីនដែលត្រូវទទួលបន្ទុកខុសត្រូវចំពោះបទបញ្ញា ការគ្រប់គ្រង និងការសម្របសម្រួលសកម្មភាពកម្ចាត់មីន។<br>សម្គាល់៖ ក្នុងករណីដែលអវត្តមាន NMAA វាអាចនឹងចាំបាច់និងសមស្របសម្រាប់អង្គការសហប្រជាជាតិ ឬស្ថាប័ន**ដ៏ទៃទៀតដែល**ទទួលស្គាល់**ដោយ**អន្តរជាតិ នឹងទទួល**នូវទំនួល**ខុសត្រូវខ្លះឬទាំងអស់ ដើម្បីបំពេញមុខងារមួយចំនួនឬទាំងអស់នៃ MAC ឬមិនសូវញឹក**ញាប់របស់** NMAA។ |
| **ការស្រាវជ្រាវមិនបច្ចេកទេស ( NTS )** | ការប្រមូល និងវិភាគទិន្នន័យដោយមិនប្រើបច្ចេកទេសអន្តរាគមន៍ **ទៅលើ**វត្តមាន ប្រភេទ របាយ និងមជ្ឈដ្ឋានជុំវិញនៃ**តំបន់ដែលមាន**យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដើម្បីកំណត់ឲ្យបានល្អប្រសើរនូវកន្លែងដែលមានវត្តមាន ឬ**កន្លែង**មិនមានវត្តមាន**របស់** EO **ហើយ**ដើម្បីគាំទ្រដល់អាទិភាព**ក្នុង**ការរំដោះផ្ទៃដី |

---

[1] ឧបករណ៍ជាតិផ្ទុះកែច្នៃ ( IEDs ) ឆ្លើយតបនឹងនិយមន័យនៃគ្រាប់មីន ខ្សែអន្ទាក់គ្រាប់មីន ឬឧបករណ៍ផ្សេងទៀតស្ថិតនៅក្រោមវិសាលភាពនៃសកម្មភាពកម្ចាត់មីន នៅពេលការបោសសម្អាតពួកវាត្រូវបានអនុវត្តក្នុងគោលបំណងមនុស្សធម៌ និងនៅក្នុងតំបន់ដែលមានការបង្ករសង្គ្រាមត្រូវបានចប់។

**រូបខាងស្តាំ៖** ក្មេងប្រុសជនជាតិកូឡុំប៊ីម្នាក់នេះមានអាយុ ១២ឆ្នាំ បានបាត់បង់ដៃឆ្វេងនៅឆ្នាំ ២០១៤ ដោយសារគ្រាប់មីន។ គាត់បានទទួលវគ្គស្តារនីតិសម្បទារាងកាយ និងការគាំទ្រផ្នែកចិត្តសាស្ត្រ។ © J.M. Vargas/អង្គការ HI

| | |
|---|---|
| ការស្រាវជ្រាវបច្ចេកទេស (TS) | សំដៅលើការប្រមូលនិង វិភាគទិន្នន័យដោយប្រើបច្ចេកទេសអន្តរាគមន៍សមស្រប ទៅលើវត្តមាន ប្រភេទ របាយ និងមជ្ឈដ្ឋានជុំវិញនៃតំបន់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដើម្បីកំណត់ឲ្យបានល្អប្រសើរនូវកន្លែងដែលយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះមានវត្តមាន ឬអវត្តមាន ហើយដើម្បីគាំទ្រដល់អាទិភាពក្នុងការរំដោះផ្ទៃដី និងដំណើរការធ្វើសេចក្តីសម្រេចចិត្តតាមរយៈការផ្តល់ភស្តុតាង។ |
| កិច្ចជួយសង្គ្រោះជនរងគ្រោះ (VA) | សំដៅទៅលើសកម្មភាពដែលត្រូវបានធ្វើឡើងដើម្បីធានាថាតម្រូវការរបស់ជនរងគ្រោះត្រូវបានឆ្លើយតប និងការគោរពសិទ្ធិទៅលើជនរងគ្រោះ។ វារួមបញ្ចូលទាំងការថែទាំវេជ្ជសាស្ត្រជាបន្ទាន់និងការបន្តទៅលើការស្តារនីតិសម្បទារាងកាយ (រួមបញ្ចូលទាំងអវយវៈសិប្បនិម្មិតនិងរណប) ការគាំទ្រផ្នែកចិត្តសាស្ត្រ-សង្គម និងការដាក់បញ្ចូលសេដ្ឋកិច្ចសង្គម ក៏ដូចជាការអភិវឌ្ឍគោលនយោបាយ |
| សំណុំសំណួរខ្លីក្រុមវ៉ាស៊ីងតោន (WGSS) | សំណុំសំណួរខ្លីក្រុមវ៉ាស៊ីងតោននៃសំនួរអំពីពិការភាព។ |



## បុព្វកថា

ឯកសារនេះ ឈរលើឯកសារបោះពុម្ពលើកទី១ដែលបានរៀបចំដោយអង្គការហេឡូត្រាស្ត (HALO) អង្គការ ម៉ែក (MAG) និង អង្គការជំនួយនៃប្រជាពលរដ្ឋន័រវេស្សេន៍ (NPA) ដោយនេះគឺជាការខិតខំប្រឹងប្រែងបង្កើតនិយមន័យរួមមួយសម្រាប់អ្នកទទួលផលលើសកម្មភាពសកម្មភាពកម្ចាត់មីន។ ដើម្បីធានាបាននូវស្តង់ដារ និងវិធីសាស្ត្រប្រៀបធៀបនូវការប្រមូលទិន្នន័យពីអ្នកទទួលផលដែលអាចយកមកប្រើប្រាស់ដោយដៃគូពាក់ព័ន្ធក្នុងសកម្មភាពកម្ចាត់មីន យើងបានប្រើប្រាស់បទពិសោធន៍របស់យើង ចែករំលែកការអនុវត្តល្អៗពីកម្មវិធីសកម្មភាពកម្ចាត់មីនទូទាំងពិភពលោក និងបទពិសោធន៍រៀនសូត្រក្នុងការកំណត់ន័យ និងកំណត់អត្តសញ្ញាណអ្នកទទួលផល។

កិច្ចខិតខំប្រឹងប្រែងនេះត្រូវបានផ្តួចផ្តើមឡើងដោយបំណងប្រាថ្នារួមសម្រាប់ការវាស់ស្ទង់ទិន្នផល និងលទ្ធផលក្នុងសកម្មភាពកម្ចាត់មីនឲ្យកាន់តែមានប្រសិទ្ធភាព។ វាត្រូវបានគេមើលឃើញថាជាមូលដ្ឋានមួយដែលគេចាត់ទុកមនុស្សជាផ្នែកដ៏សំខាន់នូវគ្រប់ទិដ្ឋភាពការងាររបស់យើង និង ដើម្បីឲ្យប្រតិបត្តិករ ម្ចាស់ជំនួយ និងអាជ្ញាធរជាតិរក្សានូវតម្រូវការ និងសេចក្តីប្រាថ្នារបស់ប្រជាជនដែលយើងបម្រើជាធំ ដោយជាដំបូងយើងត្រូវកំណត់ឲ្យច្បាស់ថាពួកគេជានរណា។ មានតែបន្ទាប់ពីការកំណត់អត្តសញ្ញាណអ្នកដែលទទួលផលប៉ុណ្ណោះទើបអាចឲ្យយើងយល់ច្បាស់ពីអាទិភាពរបស់ពួកគេ និងអាចកំណត់វិធីធ្វើការឲ្យកាន់តែប្រសើរឡើងដើម្បីឈានទៅដល់ការសម្រេចអាទិភាពទាំងនោះប្រកបដោយបរិយាប័ន្ន។

យើងជឿជាក់ថាការកំណត់ន័យ និងការរាប់អ្នកទទួលផលតាមមធ្យោបាយដែលមានអត្ថន័យនិងត្រឹមត្រូវគួរតែជាចំណុចចាប់ផ្តើមមួយសម្រាប់វិស័យសកម្មភាពកម្ចាត់មីន។ ការយល់ដឹងស៊ីជម្រៅពីលទ្ធផលការងាររបស់យើង និងវិធីសាស្ត្រវាយតម្លៃដែលមានសក្តានុពល គឺចាំបាច់សម្រាប់ប្រសិទ្ធិភាពនៃការអនុវត្តការតាមដាន និងការវាយតម្លៃនៃប្រតិបត្តិករក្នុងសកម្មភាពកម្ចាត់មីន និងសម្រាប់សមត្ថភាពនៃក្នុងការយល់ដឹងរបស់យើង ហើយវាអាចបង្ហាញយ៉ាងច្បាស់ពីផលប្រយោជន៍នៃការងាររបស់យើង។ យើងសង្ឃឹមថាឯកសារនេះ និងវិធីសាស្ត្ររួមគ្នាដែលបានអនុវត្តនៅក្នុងការអភិវឌ្ឍ នឹងក្លាយជាគ្រឹះសម្រាប់កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត។

ការបោះពុម្ពលើកទីមួយត្រូវបានបញ្ចប់ជាផ្លូវការនៅខែវិច្ឆិកា ឆ្នាំ២០១៦ និងបានដាក់បង្ហាញនៅក្នុងកិច្ចប្រជុំអន្តរជាតិរវាងនាយកនៃសកម្មភាពកម្ចាត់មីនជាតិលើកទី ២១ និងទីប្រឹក្សាអង្គការសហប្រជាជាតិនៅឆ្នាំ២០១៧។ តាំងពីពេលនោះមក និយមន័យទាំងនេះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅទូទាំងប្រទេសដែលរងផលប៉ះពាល់ ហើយត្រូវបានចាប់ផ្តើមប្រើដោយម្ចាស់ជំនួយសំខាន់ៗ និងអាជ្ញាធរសកម្មភាពកម្ចាត់មីនថ្នាក់ជាតិផងដែរ។ ការបោះពុម្ពលើកទីពីរនេះគឺជាការរួមបញ្ចូលទាំងការកែលម្អ និងការបញ្ជាក់លើនិយមន័យទាំងនេះដោយផ្អែកលើបទពិសោធន៍មូលដ្ឋាន និងការប្រឹក្សាយោបល់យ៉ាងទូលំទូលាយជាមួយនឹងអ្នកពាក់ព័ន្ធ និងប្រតិបត្តិករ ។

## គោលបំណង

ឯកសារនេះបង្ហាញពីស្តង់ដារនៃនិយមន័យ និងគោលការណ៍ណែនាំសម្រាប់ការវាស់ស្ទង់ ការកត់ត្រា និងការរាយការណ៍ពីចំនួនអ្នកទទួលផលពី EORE ការរំដោះផ្ទៃដី កិច្ចជួយសង្គ្រោះជនរងគ្រោះ និង**ការងារអន្តរាគមន៍**កម្ទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ គោលការណ៍ណែនាំនេះមិនរាប់បញ្ចូលលើនិយមន័យអ្នកទទួលផលក្នុងសសរស្តម្ភពីរដ៏ទៃទៀតនោះទេ គឺ៖ ការតស៊ូមតិ និងការបំផ្លាញឃ្លាំងស្តុក។

យើងសង្ឃឹមថាឯកសារនេះនឹងអាចត្រូវប្រើជាមគ្គុទេសក៍សម្រាប់ប្រតិបត្តិករសកម្មភាពកម្ចាត់មីន ម្ចាស់ជំនួយ និងអាជ្ញាធរជាតិផ្សេងទៀត ដើម្បីចែករំលែកការអនុវត្តល្អៗ និងចូលរួមចំណែកក្នុងស្តង់ដារអន្តរជាតិសម្រាប់វិស័យនេះលើការរាយការណ៍អ្នកទទួលផល។[2]

[2] លក្ខណៈមួយចំនួននៃនិយមន័យ និងគោលការណ៍ណែនាំទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ ខ នៃ IMAS 05.10 ក៏ដូចជា IMAS 07.10 IMAS 07.11 IMAS 09.30 TNMA 10.20/01 IMAS 12.10 និង IMAS 13.10។

ប្រតិបត្តិករគួរតែបកប្រែឯកសារនេះជាភាសាជាតិ ក្នុងខណៈ ធរជាតិ និងប្រតិបត្តិករផ្សេងទៀតដើម្បីជានាឲ្យមានការយល់ដឹង ពេលដែលមានការបកប្រែ និងពិនិត្យឡើងវិញពីសំណាក់អាជ្ញា ពេញលេញអំពីនិយមន័យនេះ។

# គោលការណ៍

និយមន័យស្តង់ដារនៃអ្នកទទួលផលនេះគឺជាការផ្អែកលើបណ្តុំនៃគោលការណ៍ដូចខាងក្រោមដើម្បីធានាបានថានិយមន័យទាំងអស់ត្រូវបានបង្កើតឡើង និងវាយតម្លៃទៅតាមលក្ខណៈវិនិច្ឆ័យដូចៗគ្នា។

ហេតុផលនៅពីក្រោយនិយមន័យទាំងអស់គួរតែមានភាពច្បាស់លាស់ និងសមហេតុផលនៅក្នុងបរិបទនៃកម្មវិធីនីមួយៗ និងគួរតែប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ខាងក្រោមនេះ៖

១ និយមន័យដែលបានប្រើគួរតែមានភាពប្រាកដនិយមតាមដែលអាចធ្វើទៅបាននៅក្នុងបរិបទនៃកម្មវិធី ដើម្បីចៀសវាងការបំប៉ោងតួលេខ។

២ និយមន័យ និងវិធីសាស្ត្រដែលបានប្រើដើម្បីរាប់អ្នកទទួលផលនៃសកម្មភាពមួយគួរតែសមាមាត្រទៅនឹងពេលវេលា និងធនធានសម្រាប់អ្នកដែលត្រូវការអនុវត្តសកម្មភាពដោយខ្លួនឯង និងគួរផ្សារភ្ជាប់ជាមួយនឹងលក្ខណៈវិនិច្ឆ័យដែលបានប្រើក្នុងការកំណត់ចំនួនប្រជាជនគោលដៅ។

៣ វិធីសាស្ត្រដែលបានប្រើដើម្បីរាប់អ្នកទទួលផលគួរតែមានតម្លាភាព ហើយនិយមន័យដែលប្រើប្រាស់ត្រូវផ្តល់ទៅឲ្យម្ចាស់ជំនួយ និងប្រជាជនដែលរងផលប៉ះពាល់។

៤ វិធីសាស្ត្រដែលប្រើដើម្បីរាប់អ្នកទទួលផលអាចមានបរិបទជាក់លាក់ ខណៈដែលនៅតែស្ថិតនៅក្នុងគោលការណ៍ណែនាំនិយមន័យសកល។

៥ វិធីសាស្ត្រដែលប្រើដើម្បីរាប់អ្នកទទួលផលគួរតែត្រូវបានសម្របសម្រួលក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ រួមមាន អាជ្ញាធរសកម្មភាពកម្ចាត់មីនថ្នាក់ជាតិ ស្ថាប័នសកម្មភាពកម្ចាត់មីនរបស់អង្គការសហប្រជាជាតិ ម្ចាស់ជំនួយ និងប្រតិបត្តិករក្នុងប្រទេសដើម្បីធានាភាពជាប់លាប់នៃវិធីសាស្ត្រ។

៦ ចំនួនអ្នកទទួលផលទាំងអស់គួរតែត្រូវបានបែងចែកទៅតាមភេទ អាយុ និង ពិការភាព (អក្សរកាត់ SADDD ដែលមានន័យថាទិន្នន័យបែងចែកតាមភេទ អាយុ និងពិការភាព) ប្រសិនជាអាចធ្វើបាន។ រីឯកុមារគួរតែត្រូវបានកំណត់ថាជាបុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ។[3] ការបែងចែកបន្ថែមអាចធ្វើបានដោយយោងទៅលើសាវតារវប្បធម៌/អត្តសញ្ញាណ។ គេទទួលស្គាល់ថានៅក្នុងស្ថានភាពខ្លះ វាអាចនឹងពិបាកក្នុងការប្រមូលយកទាំងព័ត៌មានពិការភាព និងព័ត៌មានពាក់ព័ន្ធនឹងវប្បធម៌។[4]

៧ អ្នកទទួលផលអាចត្រូវបានរាយការណ៍ច្រើនជាងម្តង ប្រសិនបើពួកគេទទួលបានផលប្រយោជន៍ពីសកម្មភាពច្រើនជាងមួយ។

៨ ក្នុងសកម្មភាពមួយ ការរាប់អ្នកទទួលផលទ្វេដងគួរតែត្រូវបានចៀសវាងក្នុងករណីដែលអាចធ្វើទៅបាន ប៉ុន្តែវាត្រូវបានទទួលស្គាល់ថាការរាប់ទ្វេដងខ្លះគឺមិនអាចចៀសរួចនោះទេ ជាពិសេសចំពោះ EORE និង **ការងារអន្តរាគមន៍** EOD។

៩ ការកើតមានឡើងនៃករណីរាប់ទ្វេដងណាមួយគួរតែត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងពេលរាយការណ៍។

[3] យោងតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិកុមារ កុមារត្រូវបានកំណត់ថាជា "មនុស្សដែលមានអាយុក្រោម ១៨ឆ្នាំ"។

[4] ទាក់ទងទៅនឹងការប្រមូលព័ត៌មានពិការភាព សេចក្តីយោងត្រូវបានធ្វើឡើងចំពោះសំណួរនៃសំណុំសំណួរខ្លីនៃក្រុមវ៉ាស៊ីនតោនស្តីពីពិការភាព ដែលបានពន្យល់ដូចខាងក្រោម។

## ការប្រមូលទិន្នន័យពាក់ព័ន្ធនឹងជនមានពិការភាព

រាល់សកម្មភាពកម្ចាត់មីនទាំងអស់គួរត្រូវធ្វើឡើងតាមលក្ខណៈដែលអាចចូលទៅប្រើប្រាស់បាន និងលើកទឹកចិត្តដល់ការរួមបញ្ចូលបរិយាប័ន្ននូវចំនួនប្រជាជនយ៉ាងទូលំទូលាយ និងចម្រុះ។ ការប្រមូលទិន្នន័យដែលបែងចែងដោយពិការភាពគឺជាមធ្យោបាយដ៏សំខាន់សម្រាប់ផ្នែកនេះ។ ប្រសិនបើសកម្មភាពទំនាក់ទំនងសហគមន៍ NTS VA[5] និង EORE មិនមានលក្ខណៈបរិយាប័ន្ន និងការអាចចូលទៅប្រើប្រាស់បានសម្រាប់ជនមានពិការភាព គម្រោងគឺមិនអាចឆ្លើយតបពេញលេញទៅនឹងតម្រូវការចម្រុះរបស់សហគមន៍ឡើយ។

គោលបំណងចម្បងសម្រាប់ការប្រមូលទិន្នន័យអំពីជនមានពិការភាពគឺ៖[6]

១. ដើម្បីទទួលបានការយល់ដឹងពីផលប៉ះពាល់នៃបញ្ហាមីនទៅលើជនមានពិការភាពក្នុងចំណោមចំនួនប្រជាជនដ៏ច្រើន ដើម្បីអាចយកមកពិចារណានៅពេលកំណត់អាទិភាពសម្រាប់ NTS TS ការបោសសម្អាត EORE និង VA។ កិច្ចការនេះរួមបញ្ចូលទាំងការប្រមូលទិន្នន័យរបស់អ្នកគ្រោះថ្នាក់ដែលត្រូវបានបែងចែកដោយពិការភាព។ តាមរយៈការយល់ដឹងថាអ្នកណាខ្លះដែលបានកំពុងរស់នៅដោយមានពិការភាពមុនពេលមានគ្រោះថ្នាក់ដោយEO ការកំណត់គោលដៅឲ្យកាន់តែប្រសើរសម្រាប់ EORE (ឧទាហរណ៍) ត្រូវបានសម្របសម្រួល។

២. ដើម្បីកំណត់ឧបសគ្គលើឥរិយាបទ រូបវន្ត ស្ថាប័ន និងទំនាក់ទំនង ដែលជាបង្អាក់ការចូលរួមរបស់ជនមានពិការភាពនៅក្នុង NTS VA និង EORE។ ជាមួយនឹងព័ត៌មានទាំងនេះ អង្គភាពអាចកែលម្អនូវកម្មវិធី និងយន្តការរបស់ខ្លួនដោយដកឧបសគ្គទាំងនោះចេញ និងដាក់ជំនួសមកវិញនូវអ្នកសម្របសម្រួលដើម្បីធានាឲ្យមានការចូលរួមរបស់ជនមានពិការ។ ព័ត៌មាននេះក៏ជូនដំណឹងអំពីការសម្រេចចិត្តលើការបណ្តុះបណ្តាលបុគ្គលិក ការលើកកម្ពស់ការយល់ដឹង និងគម្លាតនៃសមត្ថភាពនៅក្នុងអង្គភាពផងដែរ។

៣. ដើម្បីធ្វើឲ្យការធ្វើផែនការ និងការចាត់អាទិភាពរបស់គម្រោងកាន់តែប្រសើរឡើង វាពិតជាសំខាន់ខ្លាំងណាស់ដែលយើងត្រូវពិចារណាពីការយល់ឃើញ និងអាទិភាពរបស់ជនមានពិការភាព។ ដើម្បីចាប់យកទិន្នន័យបែបគុណភាពដែលចាំបាច់ ការពិភាក្សាក្រុម និងការសម្ភាសន៍ត្រូវបានណែនាំឲ្យប្រើប្រាស់។

៤. ដើម្បីតាមដានថាជនមានពិការភាពត្រូវបានជូនដំណឹងពីការធ្វើ NTS និងអត្ថប្រយោជន៍អំពីការរំដោះផ្ទៃដី CL EORE និង VA តាមភាពស្មើគ្នាទៅនឹងប្រជាជនផ្សេងៗទៀតដែរឬទេ។

៥. វាជាការកាត់បន្ថយវិសមភាព និងការកំណត់គោលដៅដល់ក្រុមពាក់ព័ន្ធដែលជាជនងាយរងគ្រោះបំផុតគឺជាអាទិភាព ទិន្នន័យអំពីជនមានពិការភាពអាចបង្ហាញថាការងាររបស់យើងបានទៅដល់ក្រុមទាំងនោះ។

សំណួរក្នុងសំណុំសំណួរខ្លីរបស់ក្រុមវ៉ាស៊ីងតោន (WGSS) គឺជាស្តង់ដារអេប្បបរមាដែលត្រូវបានណែនាំឲ្យប្រើប្រាស់សម្រាប់ការកំណត់អត្តសញ្ញាណជនមានពិការភាពនៅក្នុងសកម្មភាពកម្ចាត់មីន។ វាគួរត្រូវបានដាក់បញ្ចូលនៅពេលដែលទិន្នន័យត្រូវបានប្រមូលនៅកម្រិតបុគ្គល ឬកម្រិតគ្រួសារ និងត្រូវអនុវត្តទៅលើអ្នកដែលមានអាយុពីប្រាំមួយឆ្នាំឡើងទៅ។[7] សំណួរ WGSS មិនសមស្របប្រើប្រាស់សម្រាប់ការប្រមូលព័ត៌មាននៅកម្រិតក្រុម ឬសហគមន៍នោះទេ។

[5] លើសពីនេះ យើងមិនអាចត្រូវបានសន្មតថាសេវាកម្មដែលជនរងគ្រោះត្រូវការត្រូវបានរាប់បញ្ចូលដោយខ្លួនឯងនោះទេ។ ប្រតិបត្តិករគួរតែត្រៀមលក្ខណៈដើម្បីដាក់បញ្ចូលវាទៅក្នុងវិធីសាស្ត្រពេលប្រតិបត្តិការ។

[6] គោលដៅត្រូវបានយកលំនាំពីទម្រង់គម្រោងទាំងប្រាំពីរនៅក្នុងគោលការណ៍ណែនាំគណៈកម្មាធិការអចិន្ត្រៃយ៍អន្តរភ្នាក់ងារស្តីពីការរាប់បញ្ចូលជនមានពិការភាពនៅក្នុងសកម្មភាពមនុស្សធម៌។ ប្រតិបត្តិករត្រូវបានលើកទឹកចិត្តឲ្យអនុវត្តតាមគោលការណ៍ណែនាំ IASC ដើម្បីធានាថាសកម្មភាពត្រូវបានរាប់បញ្ចូលសម្រាប់ជនមានពិការភាព។ http://interagencystandingcommittee.org/iasc-task-inclusion-persons-disabilities-humanitarian-action/documents/iasc-guidelines

[7] សម្រាប់អ្នកដែលធ្វើការជាមួយកុមារ មានម៉ូឌែល WGSS ជាក់លាក់មួយស្តីពីមុខងារកុមារដែលបានបញ្ចប់ក្នុងឆ្នាំ២០១៦ ដែលនិយាយអំពីកុមារអាយុចម្លោះពី ២ និង១៧ឆ្នាំ សូមមើល http://data.uncief.org/resources/module-child-functioning

សំណួរទាំងនេះត្រូវបានគ្របដណ្តប់លើផ្នែកចំនួនប្រាំមួយលើមុខងារដូចជា៖ ការមើលឃើញ ការស្តាប់លឺ ការដើរ ការដឹង ការថែទាំខ្លួនឯង និងការទំនាក់ទំនង។ ផ្នែកទាំងប្រាំមួយនេះត្រូវបានជ្រើសរើសដោយសារតែវាបានបញ្ចូលនូវអ្នកដែលមានហានិភ័យបំផុតនៃការដាក់កំហិតការចូលរួម ប្រសិនបើការយកចិត្តទុកដាក់សមស្របមិនត្រូវបានធ្វើឡើង។ ហេតុដូចនេះ ទិន្នន័យនោះគួរត្រូវបានប្រើប្រាស់ដើម្បីជួយដល់ប្រតិបត្តិករ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការកំណត់ឧបសគ្គក្នុងការចូលរួមនៅក្នុងការស្រង់មតិ EORE និង VA ដែលអាចជួយឲ្យយើងលុបបំបាត់ ឬកាត់បន្ថយឧបសគ្គទាំងនេះ នឹងដើម្បីឲ្យជនមានពិការភាពអាចចូលរួមដោយផ្អែកលើមូលដ្ឋានលើភាពស្មើគ្នា។ សំណុំស្តង់ដារនៃសំណួរដែលមានកំណត់នេះក៏អាចយកមកប្រៀបធៀបនៅទូទាំងប្រទេស ឬនៅថ្នាក់តំបន់ក្រោមជាតិ និងរវាងសហគមន៍គោលដៅ និងអ្នកចូលរួមសកម្មភាពបានផងដែរ។ ព័ត៌មានលម្អិតបន្ថែមលើធនធាន និងសម្ភារបណ្តុះបណ្តាល អំពីសំណួរ និងការប្រើប្រាស់របស់អាចស្វែងរកបាននៅលើគេហទំព័រ Washington Group។[8]

ការពិពណ៌នាពីការទៅដល់និងផលប៉ះពាល់នៅកម្រិតម៉ាក្រូ ឬនៅក្នុងករណីដែលការប្រមូលព័ត៌មានដោយផ្ទាល់អំពីជនមានពិការភាពមានភាពរសើប ឬមិនអាចសម្រេចបាន ទិន្នន័យនោះប្រហែលជាអាចរកបានពីប្រភពរដ្ឋាភិបាល ឬប្រភពបន្ទាប់បន្សំផ្សេងទៀត។



**រូបភាពខាងលើ៖** តំបន់ភ្នំ Darwaz នៅភាគឦសាននៃប្រទេសអាហ្វហ្គានីស្ថាននៅតែមានបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរដោយគ្រាប់មីនប្រឆាំងមនុស្ស។ ក្មេងៗទាំងនេះមកពីភូមិ Jamarje Bala ចាំបាច់ត្រូវដឹងពីរបៀបសម្គាល់សំណល់ជាតិផ្ទុះពីសង្គ្រាម និងមិនត្រូវទៅជិតពួកវានៅពេលដែលពួកគេទៅលេងខាងក្រៅ។ ©FSD

[8] សូមមើលឧបករណ៍ការប្រមូលទិន្នន័យដែលបង្កើតឡើងដោយ WG ស្តីពីស្ថិតិជនមានពិការភាព និងការណែនាំស្តីពីការប្រើប្រាស់៖ http://www.washingtongroup-disability.com/wp-content/uploads/2016/12/WG-Document-1-Data-Collection-Tools-Developed-by-the-Washington-Goup.pdf ( ទំ.៧ ) និងឧបករណ៍សិក្សាអនឡាញ និង Webinars របស់ The Washington Group: http://www.washingtongroup-disability.com/washington-group-question-sets/e-learning-tools/

# ការអប់រំពីហានិភ័យនៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

## ការកំណត់អ្នកទទួលផល

**អ្នកទទួលផលផ្ទាល់**ត្រូវបានកំណត់ថាជាបុគ្គលដែលទទួលបានសារសុវត្ថិភាពពីការអប់រំហានិភ័យនៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ[9]៖

- តាមរយៈ EORE ការទំនាក់ទំនងរវាងអន្តរបុគ្គល;
- តាមរយៈ EORE ពីប្រព័ន្ធផ្សព្វផ្សាយធំៗ និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល;
- តាមរយៈការបណ្តុះបណ្តាលពីគ្រូបង្គោលនៅក្នុងការបណ្តុះបណ្តាល EORE ។

ការរាប់អ្នកទទួលផលផ្ទាល់គួរត្រូវបានរាយការណ៍ដាច់ដោយឡែកសម្រាប់ប្រភេទនីមួយៗនៃការបង្ហាញទាំងបីខាងលើ ហើយតួលេខមិនគួរត្រូវរួមបញ្ចូលគ្នាទេ ។ វិធីសាស្រ្តក្នុងការវាស់វែងអ្នកទទួលផលផ្ទាល់ត្រូវបានរៀបរាប់សង្ខេបនៅក្នុងតារាងខាងក្រោម ។

**អ្នកទទួលផលប្រយោល**ពី EORE រួមមានបុគ្គលដែលបានដឹងពីបុគ្គលដែលបានទទួលសារ EORE ដោយផ្ទាល់ ឧ.ឪពុកម្តាយ និងបងប្អូនរបស់កុមារដែលជាសិស្ស ។ ខណៈដែលគេយល់ថាមានអ្នកទទួលផលដោយប្រយោលពី EORE ផ្ទុយទៅវិញយើងមានការពិបាកក្នុងការគណនា ឬប៉ាន់ស្មាននៅក្នុងកម្រិតត្រឹមត្រូវមួយ ។ ហេតុដូចនេះ អ្នកទទួលផលប្រយោលមិនគួរត្រូវរាប់សម្រាប់ការអប់រំហានិភ័យនោះទេ លើកលែងតែម្ចាស់ជំនួយ ឬអាជ្ញាធរសកម្មភាពកម្ចាត់មីនថ្នាក់ជាតិស្នើសុំតែប៉ុណ្ណោះ ។

| ប្រភេទ | ពិពណ៌នា | ឧទាហរណ៍ | វិធីសាស្រ្តវាស់វែង |
|---|---|---|---|
| **EORE តាមការទំនាក់ទំនងរវាងអន្តរបុគ្គល** [*ការអប់រំ* នៅក្នុង IMAS 12.10] | វាគឺជាដំណើរការទំនាក់ទំនងទៅវិញទៅមក ទាក់ទងនឹងការផ្តល់ឲ្យ និងការទទួលបាននូវចំណេះដឹង អាកប្បកិរិយា និងការអនុវត្តតាម រយៈការបង្រៀន និងការរៀនសូត្រ ។ ទំនាក់ទំនងរវាងអន្តរបុគ្គលអាចរួមបញ្ចូលឧបករណ៍អនឡាញដរាបណាវាអាចឲ្យមានអន្តរកម្មជាមួយគ្នា ។ | សកម្មភាពតាមសហគមន៍ បទបង្ហាញ (សង្ខេប និងវែង) ការសម្តែងលើឆាក ការសម្តែងតុក្កតាអាយ៉ង ការសម្តែងវប្បធម៌ ការដាក់បញ្ចូលកម្មវិធីទៅក្នុងសាលា វគ្គជួបជុំនិម្មិតខ្នាតតូច -ល-។ | ចំនួនវត្តមាននៃអ្នកចូលរួមដែលមានអាយុប្រាំមួយឆ្នាំ ឬច្រើនជាងនេះដែលបានចូលរួមរៀនរាល់សារស្នូលនៃវគ្គសិក្សា ក្នុងនោះភេទ និងអាយុ ត្រូវបានបែកចែក ។<br>អ្នកទទួលផលនៃវគ្គសិក្សាទូលំទូលាយគួរត្រូវបានរាយការណ៍ដាច់ដោយឡែកពីវគ្គសិក្សាអាដហុក ឬវគ្គទាំងឡាយដែលកំណត់ពេលវេលា និងទំហំ ។ |
| **EORE តាមប្រព័ន្ធផ្សព្វផ្សាយធំៗ ឬប្រព័ន្ធផ្សព្វផ្សាយឌីជីថល** [*ដែលស្ថិតក្រោមការផ្សព្វផ្សាយព័ត៌មានសាធារណៈ*[10] *នៅក្នុង IMAS 12.10*] | ជាបឋម នេះជាទម្រង់នៃការទំនាក់ទំនងតែម្ខាងដែលអាចផ្តល់អោយមនុស្សជាច្រើននូវព័ត៌មាននិងដំបូន្មានដែលពាក់ព័ន្ធ ដោយចំណាយតាមបែបសន្សំសំចៃ និងទាន់ពេលវេលា ។ | ប្រព័ន្ធផ្សព្វផ្សាយធំៗ (ទូរទស្សន៍ វិទ្យុ ការបោះពុម្ពផ្សាយ)។ ប្រព័ន្ធផ្សព្វផ្សាយសង្គម/ឌីជីថល រួមទាំងកម្មវិធីផ្ញើសារ ។ | ចំនួនប្រជាជនប៉ាន់ស្មានដែលបានចូលរួមតាមរយៈយុទ្ធនាការ ក្នុងនោះភេទ និងអាយុនឹងត្រូវបែងចែកតាមដែលអាចធ្វើទៅបាន ។ |
| **ការបណ្តុះបណ្តាលគ្រូបង្គោល** [*ការបណ្តុះ* | ការបំពាក់បំប៉ន់ឲ្យអ្នកដែលនៅក្រៅវិស័យសកម្មភាពកម្ចាត់មីន ដើម្បី | ធ្វើការបណ្តុះបណ្តាលជនបង្គោលនៅក្នុងសហគមន៍ គ្រូបង្រៀន សមាជិក NGO -ល- នូវចំណេះដឹង | ចំនួនអ្នកដែលទទួលបានការបណ្តុះបណ្តាលដោយបែងចែកតាមភេទ អាយុ និងស្ថានភាពពិការភាព នៅពេលដែលអាចធ្វើទៅបាន ។ |

[9] សូមមើល IMAS 12.10

[10] ការផ្សព្វផ្សាយព័ត៌មានសាធារណៈរួមបញ្ចូលទាំងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតក្រៅពីប្រព័ន្ធផ្សព្វផ្សាយធំៗ ដូចជាផ្ទាំងផ្សព្វផ្សាយ ផ្ទាំងប្រកាស ខិត្តបណ្ណ កូនសៀវភៅផ្សព្វផ្សាយ ស្លាកផ្សព្វផ្សាយ -ល-។

| | | | |
|---|---|---|---|
| *បណ្តាលនៅក្នុង* IMAS 12.10] | ធ្វើការបង្រៀនវគ្គ EORE ឬបញ្ជូនសារដែលពាក់ព័ន្ធនឹង EORE។ | និង/ឬ សម្ភារដែលចាំបាច់ដើម្បីផ្សព្វផ្សាយសារ EORE។ | |

## គោលការណ៍ណែនាំស្តីពីការវាស់វែង និងការរាយការណ៍ពីអ្នកទទួលផល EORE

- ការខិតខំប្រឹងប្រែងដើម្បីឲ្យបានដល់ជនមានពិការភាពគួរត្រូវបានរាយការណ៍ ទោះជាយ៉ាងណា វាត្រូវបានគេយល់ថាការរួមបញ្ចូលនៃសំណួរ WGSS ទៅក្នុងវគ្គ EORE ដែលមិនអាចធ្វើបានជាទូទៅ (សូមមើលគោលការណ៍ខាងក្រោម)។
- គេបានទទួលស្គាល់ថាការរាប់ទ្វេដងនៃអ្នកទទួលផលផ្ទាល់ EORE ប្រហែលជាចៀសមិនរួចនោះទេ (ដោយសារកំណត់ត្រានៃអ្នកចូលរួមនីមួយៗមិនត្រូវបានរក្សាទុក)។ យ៉ាងណាមិញ ប្រតិបត្តិករត្រូវបានណែនាំឲ្យធ្វើការកត់ត្រាដាច់ដោយឡែកនូវចំនួនបុគ្គលដែលជាអ្នកទទួលផលចូលរួមលើកទីមួយនៅក្នុងវគ្គសិក្សាវាងអន្តរបុគ្គល។ កិច្ចការនេះមានសារសំខាន់ជាពិសេសក្នុងចំណោមបញ្ហាដទៃ នៅក្នុងស្ថានភាពនៃជម្លោះដែលកំពុងបន្តនាពេល
  បច្ចុប្បន្នដែលបណ្តាលឲ្យមានបញ្ហាយុទ្ធភណ្ឌមិនទាន់ផ្ទុះ។ ក្នុងស្ថានភាពដែលចលនាផ្លាស់ទីលំនៅ/ ជនភៀសខ្លួន មានន័យថាមនុស្សប្រឈមនឹងហានិភ័យនៅក្នុងតំបន់ដែលពួកគេមិនស្គាល់ច្បាស់ជាមួយនឹងស្ថានភាព និងទំហំនៃបញ្ហា និងនៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយបញ្ហារយៈពេលវែង ដែល EORE ត្រូវតែដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាលា។[11]
- អ្នកទទួលផលផ្ទាល់នៃប្រព័ន្ធផ្សព្វផ្សាយឌីជីថល (ប្រព័ន្ធផ្សព្វផ្សាយសង្គម/សារខ្លី) អាចត្រូវបានគណនាដោយប្រើប្រាស់ទិន្នន័យដែលបានផ្តល់ដោយអ្នកផ្តល់សេវាប្រព័ន្ធផ្សព្វផ្សាយ (ឧ. ចំនួនអ្នកប្រើប្រាស់ក្នុងតំបន់ដែលបានកំណត់ អ្នកប្រើប្រាស់ពិសេស តំណភ្ជាប់ដែលបានចុច មតិយោបល់ដែលបានផ្តល់ជាដើម)។ ការប៉ាន់ស្មានទាំងនេះគួរតែនៅកម្រិតទូទៅដែលបង្ហាញពីលទ្ធភាពទៅដល់តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងនៅកម្រិតបន្ទាប់បន្សំគួរផ្តល់ព័ត៌មានពីចំនួនមនុស្សប៉ុន្មាននាក់ដែលធ្វើអន្តរកម្មតាមវិធីដែលអាចរាប់បាន។ នៅពេលដែលអាចធ្វើទៅបាន ទីតាំងភូមិសាស្ត្រនៃអ្នកប្រើប្រាស់គួរត្រូវបានកត់ត្រា និងរាយការណ៍ដើម្បីកំណត់ថាតើសារបានទៅដល់ក្រុមមនុស្សគោលដៅដែរឬទេ។
- អ្នកទទួលផលផ្ទាល់នៃប្រព័ន្ធផ្សព្វផ្សាយធំៗ[12] (ការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ការបោះពុម្ពផ្សាយ/ប្រព័ន្ធផ្សព្វផ្សាយអនឡាញ) អាចត្រូវបានប៉ាន់ស្មានដោយប្រើប្រាស់តួលេខនៃការផ្សព្វផ្សាយសម្រាប់ប្រព័ន្ធផ្សព្វផ្សាយលើ ថ្ងៃ និងចំនួនដងនៃការផ្សព្វផ្សាយ នៅពេលដែលអាចប្រើប្រាស់បាន ឬចំនួនអតិថិជន។ នៅពេលដែលមិនអាចរកនូវទិន្នន័យវិទ្យុ/ទូរទស្សន៍បាន អ្នកទទួលផលផ្ទាល់អាចត្រូវបានប៉ាន់ស្មានដោយយោងទៅតាមភូមិសាស្ត្រដែលបណ្តាញវិទ្យុ/ទូរទស្សន៍អាចទៅដល់ និងចំនួនមធ្យមនៃអ្នកស្តាប់/មើល ដែលបានប៉ាន់ស្មាននៅពេលដែលសារ EORE ត្រូវបានផ្សព្វផ្សាយ។ ការចែកចាយសារទៅតាមទីតាំងភូមិសាស្ត្រគួរត្រូវបានកត់ត្រា និងរាយការណ៍ដើម្បីកំណត់ថាតើតំបន់ដែលប៉ះពាល់ដោយសារគ្រាប់មីនណាខ្លះដែលមិនអាចចូលទៅដល់បាន និងផ្ទុយមកវិញ ថាតើសារនោះបានរីករាលដាលឆ្ងាយពេកដែលនាំឲ្យមានការភ័យខ្លាចដែលមិនចាំបាច់ដែរឬទេ។ តួលេខដែលត្រូវបានបំប៉ោងគួរត្រូវបានចៀសវាង ដូចបានគូសបញ្ជាក់នៅក្នុងគោលការណ៍ណែនាំនេះ។ ជាពិសេស ប្រសិនបើសារត្រូវបានផ្សព្វផ្សាយម្តងហើយម្តងទៀត ឬជាផ្នែកមួយនៃវគ្គបន្តបន្ទាប់គ្នា ប្រតិបត្តិករមិនត្រូវគុណចំនួនអ្នកទស្សនា ឬអ្នកស្តាប់ជាមួយនឹងចំនួននៃការផ្សព្វផ្សាយឡើយ។ ប្រតិបត្តិករត្រូវរាយការណ៍តួលេខមធ្យមនៃអ្នកទស្សនា/អ្នកស្តាប់តែម្តងសម្រាប់លំដាប់លំដោយនៃការផ្សព្វផ្សាយទាំងមូល។
- អ្នកទទួលផលផ្ទាល់ពីការបណ្តុះបណ្តាលគ្រូបង្គោលគឺជាអ្នកទាំងឡាយណាដែលនឹងត្រូវទៅធ្វើការបណ្តុះបណ្តាល EORE តែប៉ុណ្ណោះ។ ឧទាហរណ៍ ជនបង្គោលក្នុងសហគមន៍ និងគ្រូបង្រៀន និងអ្នកទាំងឡាយណាដែលនៅក្រៅវិស័យសកម្មភាពកម្ចាត់មីន ដែលនឹងត្រូវបណ្តុះបណ្តាលអ្នកដទៃពីវិធីបញ្ជូនសារ EORE (បណ្តុះបណ្តាលគ្រូបង្គោល)។ វាមិនរួមបញ្ចូល EORE បែបស្ថាប័ន ដែលពេលខ្លះសំដៅលើ "ការបណ្តុះបណ្តាល" នោះទេ។
- តាមច្បាប់ទូទៅ អ្នកទទួលផលផ្ទាល់មិនគួរត្រូវបានរាប់ នាពេលដែលពួកគាត់ទទួលសម្ភារព័ត៌មាន អប់រំ និងទំនាក់ទំនង (IEC) ដូចជាប័ណ្ណប្រកាស ផ្ទាំងផ្សព្វផ្សាយ ផ្ទាំងគំនូរលើជញ្ជាំង ខិត្តបណ្ណ ស្លាកផ្សព្វផ្សាយ -ល- ឡើយ។ លើសពីនេះ សកម្មភាពនេះត្រូវបានគេណែនាំឲ្យរាយការណ៍ជាចំនួននៃវត្ថុដែលបានដំឡើង ឫចែកចាយ។ ករណីលើកលែងអាចរួមបញ្ចូលករណីដែល IEC មានមធ្យោបាយ EORE ចម្បង ឧ. នៅ

[11] EORE ដែលបានផ្តល់ដោយសាលាតម្រូវឲ្យក្រសួងអប់រំផ្តល់ការណែនាំនៅក្នុងប្រព័ន្ធអប់រំអំពីរបៀបរាប់អ្នកទទួលផល និងថាតើត្រូវរាប់អ្នកទទួលផលលើកទីមួយផងដែរឬទេ។ វាត្រូវបានណែនាំឲ្យរាប់សិស្សដែលបានទទួលផលពី EORE តែម្តងក្នុងមួយឆ្នាំ និងថាតើវាគឺជាលើកដំបូងបំផុតរបស់ពួកគេដែរឬទេ។

[12] នៅក្នុងស្ថានភាពជាក់លាក់ វិធីសាស្ត្រផ្សព្វផ្សាយដូចគ្នាអាចត្រូវបានចាត់ថ្នាក់ថាជាប្រព័ន្ធផ្សព្វផ្សាយធំៗ ឬ IEC។ ភាពខុសគ្នានៅត្រង់ថាតើមានវិធី ដែលគួរឲ្យទុកចិត្តដើម្បីប៉ាន់ស្មានចំនួនប្រជាជនដែលទទួលបានសារតាមរយៈមធ្យោបាយនេះដែរឬទេ។ ឧ. ការប្រើប្រាស់ឧបករណ៍បំពងសម្លេង អាចជាផ្នែកមួយនៃយុទ្ធនាការគោលដៅដែលមានបំណងផ្តោតលើក្រុមអ្នកទទួលផលជាក់លាក់ (ប្រព័ន្ធផ្សព្វផ្សាយធំៗ) ដែលងាយស្រួលប៉ាន់ស្មានតួលេខ ឬវាអាចជាផ្នែកមួយនៃការគ្រប់ដណ្តប់សរុប (IEC) នៅពេលដែលចំនួនអ្នកទទួលផលមានការពិបាកក្នុងការធ្វើការប៉ាន់ស្មានឲ្យបានត្រឹមត្រូវ។

ក្នុងយុទ្ធនាការ EORE បន្ទាន់ សម្រាប់ប្រជាជនដែលពិបាកចូលទៅដល់។

- វាជាការសំខាន់ដែលយើងត្រូវបញ្ជាក់ថាតួលេខនៃក្រុមអ្នកទទួលផល EORE ផ្សេងគ្នា មិនគួរត្រូវបានដាក់រួមគ្នាដើម្បីទទួលបានចំនួនសរុប ដែលនេះតួលេខអាចនឹងត្រូវបានបំប៉ោង។ លើសពីនេះ ដោយសារអ្នកទទួលផលអាចត្រូវបានរាប់ច្រើនជាងម្តងសម្រាប់សកម្មភាព EORE នីមួយៗ ឧ. ដោយសារតែពួកគេបានចូលរួមវគ្គប្រជុំច្រើនជាងមួយ វាជាការសំខាន់ដែលយើងមិនត្រូវធ្វើការសន្មត់អំពី “ការគ្របដណ្តប់សរុប” ដែលសម្រេចបាននៅពេលដែលចំនួនអ្នកទទួលផលឡើងដល់ ឬឈានទៅដល់តួលេខប្រជាជនសរុបនៃតំបន់ដែលបានកំណត់។
- ការរាយការណ៍គួរបែងចែកឲ្យបានច្បាស់ពីប្រភេទខុសៗគ្នានៃ EORE និងផ្តោតលើការបែងចែកទិន្នន័យដែលជាផ្នែកមួយនៃការវិភាគទិន្នន័យ។ ជាទូទៅ សកម្មភាពណាមួយគួរត្រូវបានពិពណ៌នា និងរាប់ ទោះបីជាវាមានការលំបាកក្នុងការប៉ាន់ស្មានចំនួនអ្នកទទួលផលផ្ទាល់ក៏ដោយ។
- ខណៈពេលដែលវាត្រូវបានគេសន្មត់ថាសកម្មភាព EORE ផ្តល់ប្រយោជន៍ឲ្យអ្នកទទួល ការរាប់អ្នកទទួលផលមិនអាចបង្ហាញអំពីការផ្លាស់ប្តូរអាកប្បកិរិយាដែលយើងចង់បាន ឬការកើនឡើងសន្តិសុខ និងសុវត្ថិភាពបណ្តាលមកពីសកម្មភាពនេះបានឡើយ។ ហេតុដូចនេះ អ្នកប្រតិបត្តិ EORE គួរមានយន្តការ M&E សម្រាប់អនុវត្តដើម្បីវាយតម្លៃលទ្ធផលភ្លាមៗ និងលទ្ធផលមធ្យម និងសូចនាករផលប៉ះពាល់។

# ការរំដោះផ្ទៃដី

## ការកំណត់អ្នកទទួលផល

អ្នកទទួលផលពីការរំដោះផ្ទៃដី[13] គួរត្រូវបានរាប់សម្រាប់តែដីដែលត្រូវបានបោសសម្អាត និងបានកាត់បន្ថយតែប៉ុណ្ណោះ។ វិធានការទូទៅគឺមិនមានអ្នកទទួលផលណាគួរត្រូវបានរាប់ចេញពីដីដែលត្រូវបានលុបចោលឡើយ។ ការលើកលែងអាចរួមបញ្ចូលក្នុងករណីដែលមានភស្តុតាងជាឯកសារចងក្រងជាក់លាក់ថាដីនោះមិនអាចប្រើប្រាស់បានដោយសារតែការភ័យខ្លាច ឬសង្ស័យ ***និង*** បន្ទាប់ពីការស្រាវជ្រាវមិនបច្ចេកទេស អ្នកទទួលផលអាចត្រូវបានកំណត់យ៉ាងច្បាស់ថាជាអ្នកដែលប្រើប្រាស់/នឹងប្រើប្រាស់ដីនោះ (ករណីនេះអាចអនុវត្តក្រោយជម្លោះ ការរៀបចំទីក្រុង ជាដើម)។

**អ្នកទទួលផលផ្ទាល់** ត្រូវបានកំណត់ថាជាបុគ្គល (ស្ត្រី កុមារី កុមារា និងបុរស) ដែលជីវិត និងអវៈយវៈរបស់ពួកគេត្រូវបានការពារពីព្រោះពួកគេប្រើប្រាស់/នឹងប្រើប្រាស់ជារូបវន្តនូវដីដែលបានបោសសម្អាត និងកាត់បន្ថយក្រោយបោសសម្អាតសម្រាប់សកម្មភាពប្រកបដោយផលិតកម្ម និង/ឬញឹកញាប់ និង/ឬប្រកបដោយនិរន្តភាព។[14] បន្ថែមពីនេះ បុគ្គលផ្សេងទៀតដែលរស់នៅក្នុងគ្រួសារគួរត្រូវបានរាប់ថាជាអ្នកទទួលផលផ្ទាល់ ព្រោះពួកគេអាចនឹងរងផលប៉ះពាល់ដោយផ្ទាល់ដោយសារតែមរណៈភាព ឬការរងរបួសនៃអ្នកប្រើប្រាស់ដី។

**អ្នកទទួលផលប្រយោល** ត្រូវបានកំណត់ថាជាបុគ្គលទាំងឡាយដែលអាចនឹងទទួលផលពីដីដែលបានបោសសម្អាត ព្រោះតែពួកគេជាសមាជិករបស់សហគមន៍តែមួយជាមួយនឹងអ្នកទទួលផលផ្ទាល់ ប៉ុន្តែពួកគេមិនបានប្រើប្រាស់ដីដែលបានបោសសម្អាតដោយផ្ទាល់នោះទេ។ អត្ថប្រយោជន៍ទាំងនេះអាចកើតឡើងដោយឯកឯងនៅក្នុងស្ថានភាពសេដ្ឋកិច្ចដែលប្រសើរឡើងជារួមនៅក្នុងសហគមន៍ ការកាត់បន្ថយហានិភ័យ ឬជីវភាពរស់នៅទូទៅមានភាពប្រសើរឡើង។ ដើម្បីឲ្យមានភាពជាប់លាប់សម្រាប់បរិបទទូទាំងប្រទេស អ្នកទទួលផលប្រយោលគួរត្រូវបានរាប់ដោយប្រើប្រាស់ទិន្នន័យចំនួនប្រជាជនសម្រាប់អង្គភាពរដ្ឋបាលតូចបំផុត[15] ដែលនៅជិតបំផុតទៅនឹងដីដែលបានបោសសម្អាតឬកាត់បន្ថយរួច ហើយដកនឹងចំនួនអ្នកទទួលផលផ្ទាល់។

ប្រភេទការប្រើប្រាស់ដីចំនួនប្រាំមួយត្រូវបានកំណត់នៅក្នុងតារាងខាងក្រោម។ វាបានផ្តល់នូវការណែនាំពាក់ព័ន្ធនឹងវិធីក្នុងការរាប់ និងកំណត់អ្នកទទួលផលផ្ទាល់ដោយផ្អែកលើវិធីដែលដីត្រូវបានរំពឹងទុកថានឹងត្រូវបានប្រើប្រាស់ពីប្រាំមួយទៅដប់ពីរខែបន្ទាប់ពីបានរំដោះ។

**រូបភាពខាងក្រោម៖** ការប្រមូលផលខ្ទឹមបារាំងពីដីដែលបានបោសសម្អាតនៅក្នុងប្រទេសស្រីលង្កា។ © អង្គការ HALO Trust

[13] សូមមើល IMAS 07.11 សម្រាប់និយមន័យពាក្យគន្លឹះពាក់ព័ន្ធនឹងការរំដោះផ្ទៃដី

[14] សូមមើល IMAS 05.10 ឧបសម្ព័ន្ធ B

[15] អង្គភាពរដ្ឋបាលតូចបំផុតអាចត្រូវបានកំណត់ថាជាផ្នែករដ្ឋបាលកម្រិតទីបួន (ឬតូចជាងនេះ) នៅក្នុងប្រទេសមួយ៖ https://en.wikipedia.org/wiki/List_of_administrative_divisions_by_country។ ទោះជាយ៉ាងណា នៅក្នុងបរិបទទីក្រុង តំបន់ជិតខាងឬអគារអាចប្រើប្រាស់ជាអង្គភាពរដ្ឋបាលតូចបំផុត។ នៅក្នុងបរិបទជនបទមួយចំនួន អង្គភាពរដ្ឋបាលតូចបំផុតដូចដែលបានកំណត់ដោយរដ្ឋាភិបាលជាតិនីមួយៗអាចនៅធំពេក ហើយនៅក្នុងករណីនេះ វាគួរត្រូវបានកំណត់ជាភូមិឬក្រុងវិញ។ ត្រូវប្រឹងប្រែងឲ្យមានកិច្ចព្រមព្រៀងរវាងអ្នកពាក់ព័ន្ធក្នុងប្រទេស ប៉ុន្តែគួរប្រកាន់ខ្ជាប់គោលការណ៍ដើម្បីជៀសវាងការបំប៉ោងតួលេខ។ វាអាចជាចំណុចសំខាន់ជាពិសេសនៅពេលដែលតួលេខចំនួនប្រជាជនមិនត្រឹមត្រូវដោយសារតែជម្លោះ ការផ្លាស់ជម្រក ឬវត្តមាននៃក្រុមពនេចរ។

**រូបភាពខាងស្តាំ៖** ជីវិតនៅលើអតីតតំបន់មានគ្រាប់មីននៅក្នុងប្រទេសស៊ូដង់ខាងត្បូង។ © Sean Sutton/អង្គការ MAG





## ប្រភេទនៃការប្រើប្រាស់ដី និង និយមន័យអ្នកទទួលផលផ្ទាល់

| ការប្រើប្រាស់ដីដែលរំពឹងទុក | និយមន័យអ្នកទទួលផលផ្ទាល់ |
|---|---|
| **លំនៅដ្ឋាន**<br>ការស្តារនីតិសម្បទា/សាងសង់ផ្ទះ និងការតាំងទីលំនៅ រួមទាំងទីលំនៅអចិន្ត្រៃយ៍ បរិវេណ ជម្រកបណ្តោះអាសន្ន ជម្រកអាសន្នបន្ទាន់ ការតាំងទីលំនៅបណ្តោះអាសន្ន។ | ចំនួនមនុស្សក្នុងគ្រួសារដែលរស់នៅ/នឹងត្រូវរស់នៅ ឬដែល/នឹងត្រូវតាំងទីលំនៅនៅក្នុងផ្ទះ/បរិវេណ/ទីលំនៅ/ទីជម្រកនៅលើដីដែលបានរំដោះ។ |
| **កសិកម្ម**<br>ការដាំដុះ សួនកសិផលខ្នាតតូច និងការចិញ្ចឹមសត្វដែលស៊ីស្មៅជាអាហារ (ដែលទាក់ទងនឹងប្រទេស)។ | ចំនួនមនុស្សនៅក្នុងគ្រួសារ (រួមទាំងកម្មករ ប្រសិនបើពាក់ព័ន្ធ) ដែលប្រើប្រាស់/នឹងប្រើប្រាស់ដីដែលបានរំដោះដើម្បីដាំដុះដំណាំ សួនកសិផលខ្នាតតូច ឬចិញ្ចឹមសត្វដែលស៊ីស្មៅជាអាហារ ។ |
| **សេវាសហគមន៍/សាធារណៈ**<br>សេវាសាធារណៈដូចជា មណ្ឌលសុខភាព អគារសិក្សា សួនកុមារ និងបរិវេណសម្រាប់ក្មេងលេង ហាងនិងផ្សារ អគាររដ្ឋបាល/សហគមន៍ និងទីតាំងសម្រាប់វប្បធម៌ សាសនា និងការកម្សាន្ត។ | ចំនួនមនុស្សនៅក្នុងគ្រួសារដែលប្រើប្រាស់/នឹងប្រើប្រាស់ ឬកំពុងធ្វើការ/នឹងធ្វើការនៅក្នុងអគារ[16] នៅលើដីដែលបានរំដោះ។ |
| **ធនធានធម្មជាតិ**<br>ការបរបាញ់ ការរកចំណី ការប្រមូលវត្ថុធាតុដើមធម្មជាតិ ការប្រើប្រាស់ធនធានទឹកធម្មជាតិ (រួមទាំងការប្រើប្រាស់ក្នុងគ្រួសារដូចជាសម្រាប់ចម្អិនអាហារ ងូត ឬងូតទឹកឲ្យសត្វ និងការនេសាទ)។ ការចិញ្ចឹមសត្វស៊ីស្មៅទ្រង់ទ្រាយធំអាចស្ថិតក្នុងប្រភេទនេះប្រសិនបើភាគច្រើនទាក់ទងនឹងប្រទេស។ | ចំនួនមនុស្សនៅក្នុងគ្រួសារដែលប្រើប្រាស់ជាញឹកញាប់[17]/ដែលនឹងប្រើប្រាស់ញឹកញាប់នូវដីដែលបានរំដោះដើម្បីរកចំណី នេសាទ បរបាញ់ ប្រមូលវត្ថុធាតុដើម ប្រើប្រាស់ធនធានទឹកធម្មជាតិ ឬចិញ្ចឹមសត្វស៊ីស្មៅទ្រង់ទ្រាយធំ។ |
| **ហេដ្ឋារចនាសម្ព័ន្ធ (ខ្នាតតូច និងមធ្យមតែប៉ុណ្ណោះ)[18]**<br>ដីដែលបានរំដោះសម្រាប់ការប្រើប្រាស់/សាងសង់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច-មធ្យមប្រកបដោយសុវត្ថិភាព ដូចជា ហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រ អណ្តូងខួង អណ្តូងជីក ខ្សែភ្លើងថាមពលក្នុងតំបន់ ជាដើម។ | ចំនួនមនុស្សនៅក្នុងគ្រួសារដែលជាញឹកញាប់ប្រើប្រាស់/ដែលនឹងប្រើប្រាស់ញឹកញាប់នូវហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច-មធ្យម ដូចជា ហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រ អណ្តូងខួង អណ្តូងជីក ប្រភព/ខ្សែភ្លើងថាមពលក្នុងតំបន់ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ -ល- នៅលើដីដែលបានរំដោះ។ |
| **ការចូលប្រើប្រាស់ (រួមទាំងផ្លូវ និងស្ពាន)**<br>ដីដែលបានរំដោះសម្រាប់ការប្រើប្រាស់/សាងសង់/កែកុនឡើងវិញនូវផ្លូវចូលប្រកបដោយសុវត្ថិភាព រួមទាំង ផ្លូវតភ្ជាប់ ផ្លូវ និងស្ពាន។ | ចំនួនមនុស្សនៅក្នុងគ្រួសារដែលប្រើប្រាស់/នឹងប្រើប្រាស់ផ្លូវតភ្ជាប់ ផ្លូវ ឬស្ពានជាផ្លូវប្រើប្រាស់សំខាន់ៗ និង/ឬចំនួនមនុស្សដែលនឹងធ្វើដំណើរឆ្លងកាត់ជាទៀងទាត់[19] តាមរយៈដីដែលបានរំដោះដើម្បីចូលទៅកាន់ដីរបស់ពួកគេ។ |

---

[16] សេវាកម្មគ្របដណ្តប់បរិវេណធំ (ឧ. មន្ទីរពេទ្យស្រុក/អគារបែងចែកជាផ្នែក) មានការពិបាកក្នុងការកំណត់បរិមាណអ្នកទទួលផល ហើយគួរត្រូវបានដាក់ដាច់ដោយឡែកពីការរាប់អ្នកទទួលផលនេះដើម្បីជៀសវាងការបំប៉ោងទិន្នន័យ និងការបកស្រាយខុសនៃអត្ថប្រយោជន៍។ អ្នកទទួលផលនៃសេវាកម្មទាំងនេះត្រូវរាយការណ៍តាមរយៈមធ្យោបាយផ្សេងទៀត ឧ. ករណីសិក្សាជាក់លាក់។

[17] សេវាកម្មផ្សេងគ្នាអាចមាននិយមន័យនៃពាក្យថា «ញឹកញាប់» ផ្សេងគ្នាទាក់ទងនឹងការប្រើប្រាស់។ ពាក្យទាំងនេះគួរត្រូវបានកំណត់ដើម្បីឆ្លុះបញ្ចាំងបរិបទនៃកម្មវិធីនីមួយៗ និងត្រូវស្របគ្នាជាមួយនឹងស្តង់ដារជាតិ (ឧ. នៅក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)

[18] អ្នកទទួលផលនៃហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ (ឧ. ខ្សែផ្លូវរថភ្លើង ខ្សែភ្លើងមេ ជាដើម) មានការពិបាកក្នុងការកំណត់បរិមាណអ្នកទទួលផល ហើយគួរត្រូវបានរាយការណ៍ដាច់ដោយឡែកពីគ្នាពីការរាប់អ្នកទទួលផលផ្ទាល់ និងប្រយោលដើម្បីជៀសវាងការបំប៉ោងទិន្នន័យ និងការបកស្រាយខុសនៃអត្ថប្រយោជន៍។ អ្នកទទួលផលនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះគួរត្រូវបានរាយការណ៍តាមមធ្យោបាយផ្សេងទៀត ឧ. ករណីសិក្សាជាក់លាក់។

[19] «ជាទៀងទាត់» ត្រូវបានឲ្យនិយមន័យថាម្តង ឬច្រើនជាងម្តងក្នុងមួយសប្តាហ៍។ ដើម្បីគណនាការប្រើប្រាស់ជាទៀងទាត់នៃផ្លូវតភ្ជាប់ និងផ្លូវ ចំនួនមធ្យមនៃមនុស្សក្នុងមួយថ្ងៃត្រូវបានណែនាំឲ្យប្រើប្រាស់។ ទោះជាយ៉ាងណា ត្រូវមានការស្វែងរកការព្រមព្រៀងទៅលើនិយមន័យពីចំណោមប្រតិបត្តិករនៅក្នុងប្រទេស។

# គោលការណ៍ណែនាំស្តីពីការវាស់វែង និងរាយការណ៍ពីអ្នកទទួលផលពីការរំដោះផ្ទៃដី

- អ្នកទទួលផលអាចត្រូវបានរាប់នៅដំណាក់កាលផ្សេងៗគ្នានៃសកម្មភាព៖ មុនបោសសម្អាត (អ្នកទទួលផលដែលបានស្មានទុកមុន) ឬ ក្រោយបោសសម្អាត[20] (អ្នកទទួលផលជាក់ស្តែង)។ វាគួរត្រូវបានបញ្ជាក់ឲ្យច្បាស់ថាតួលេខដែលបានរាយការណ៍គឺជាតួលេខមុន ឬក្រោយបោសសម្អាត។ ជាពិសេស គួរកត់សម្គាល់ថាពាក្យថាស្មានទុកមុនមិនមែនមានន័យថាអ្នកទទួលផលដែលបានរាប់មុនបោសសម្អាតជាចំនួនប៉ាន់ស្មាននោះទេ។ អ្នកទទួលផលត្រូវបានរាប់តាមរយៈដំណើរការសម្រង់មតិធម្មតា (NTS ការសម្រង់មតិតាមគ្រួសារ ការសម្រង់មតិតាមសហគមន៍ ការចុះឈ្មោះអ្នកផ្លាស់ទីលំនៅដែលត្រឡប់មកវិញជាដើម) ប៉ុន្តែការប្រើប្រាស់ដីជាក់ស្តែងរបស់ពួកគេត្រូវបានប៉ាន់ស្មានជាមុន និងមិនត្រូវបានដឹងរហូតទាល់តែការរំដោះផ្ទៃដីបានបញ្ចប់ព្រោះវាអាចមានកត្តាផ្សេងៗដែលរារាំងការប្រើប្រាស់ដីរបស់ពួកគេនៅក្នុងអំឡុងពេលប្រាំមួយទៅដប់ខែ។
- ក្នុងករណីលើកលែងដែលមានការចែងផ្សេងពីនេះដោយម្ចាស់ជំនួយសម្រាប់ការរាយការណ៍ទៅម្ចាស់ជំនួយក្នុងរយៈពេលនៃកិច្ចសន្យា អ្នកទទួលផលដែលបានស្មានទុកជាមុនគួរត្រូវបានរាយការណ៍នៅពេលដែលកិច្ចការនីមួយៗបានចាប់ផ្តើមដោយក្រុមការងារនៃកិច្ចសន្យារបស់ម្ចាស់ជំនួយនោះ ហើយគួររាប់តែម្តងប៉ុណ្ណោះសម្រាប់កិច្ចការនីមួយៗ (សម្រាប់អ្នកទទួលផលផ្ទាល់) និងអង្គភាពរដ្ឋបាលតូចបំផុត (សម្រាប់អ្នកទទួលផលប្រយោល) ក្នុងរយៈពេលនៃកិច្ចសន្យារបស់ម្ចាស់ជំនួយ។ នៅពេលដែលប្រមូលចំនួនអ្នកទទួលផលជាក់ស្តែងបានហើយ តួលេខទាំងនេះគួរត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់អ្នកទទួលផលដែលបានស្មានទុកជាមុន ហើយត្រូវមានការផ្តល់ដំណឹងដល់ម្ចាស់ជំនួយជានិច្ចអំពីរាល់ការផ្លាស់ប្តូរ និងមូលហេតុនៃការផ្លាស់ប្តូរ។
- ការរាប់អ្នកទទួលផលជាក់ស្តែងជាធម្មតាគួរត្រូវបានធ្វើឡើងពីប្រាំមួយទៅដប់ពីរខែបន្ទាប់ពីការបោសសម្អាតបានបញ្ចប់។ យ៉ាងណាមិញ ត្រូវមានការពិចារណាទៅលើការប្រើប្រាស់ដីដើម្បីអាចរាប់អ្នកទទួលផលនៅពេលដែលមានការប្រើប្រាស់ខ្ពស់បំផុត៖ ឧ. ប្រសិនបើជាដីកសិកម្ម ការរាប់អ្នកទទួលផលក្រោយបោសសម្អាតយកល្អគួរធ្វើឡើងក្នុងអំឡុងរដូវកាលប្រមូលផល ឬព្យួររាស់ ដែលអាចនឹងលឿនជាងប្រាំមួយខែ។ អ្នកទទួលផលក៏អាចនឹងត្រូវបានរាប់នៅពេលក្រោយដែលជាផ្នែកមួយនៃលទ្ធផលឬការវាយតម្លៃផលប៉ះពាល់រយៈពេលវែង។ យ៉ាងណាមិញ អ្នកទទួលផលគួរត្រូវបានគណនាក្នុងអំឡុងពេលមុនបោសសម្អាតដោយផ្អែកលើការប្រើប្រាស់ដីដែលបានរំពឹងទុកពីប្រាំមួយទៅដប់ពីរខែក្រោយបោសសម្អាត។
- ការរាប់អ្នកទទួលផលសម្រាប់ម្ចាស់ជំនួយត្រូវបានរាយការណ៍ទៅតាមកិច្ចសន្យានីមួយៗ។ ហេតុដូចនេះ ការរាប់ចំនួនអ្នកទទួលផលទ្វេដងត្រូវបានរំពឹងទុកថាកើតឡើងនៅក្នុងវដ្តនៃកិច្ចសន្យាផ្សេងៗគ្នា ហើយម្ចាស់ជំនួយមិនត្រូវរួបរួមតួលេខនៃអ្នកទទួលផលរបស់ពួកគេនៅក្នុងមួយកិច្ចសន្យានីមួយៗទេ។ សម្រាប់ផ្ទៃក្នុង អ្នកទទួលផលនៃកិច្ចការនីមួយៗគួរត្រូវបានរាយការណ៍តែម្តងប៉ុណ្ណោះ ដូច្នេះពួកគេនឹងមិនត្រូវបានរាប់ទ្វេដងនៅក្នុងរបាយការណ៍អង្គភាពឡើយ (ឧ. របាយការណ៍ប្រចាំឆ្នាំ)។
- នៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន បុគ្គលតែមួយអាចជាអ្នកទទួលផលផ្ទាល់ពីកិច្ចការច្រើនជាមួយ (ឧ. គ្រួសារមួយអាចទទួលផលផ្ទាល់ពីការបោសសម្អាតដីកសិកម្មរបស់ពួកគេ ហើយក្រោយមកទៀតក្នុងនាមជាអ្នកប្រើប្រាស់អគារសហគមន៍នៅលើដីដែលបានរំដោះ)។ ការចៀសវាងការរាប់អ្នកទទួលផលទ្វេដងសម្រាប់កាលៈទេសៈទាំងនេះអាចតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងដែលមិនសមាមាត្រក្នុងការកត់ត្រា និងការផ្ទៀងផ្ទាត់ឆ្លងគ្នាទៅលើអត្តសញ្ញាណរបស់បុគ្គល។ នៅពេលដែលវាត្រូវបានពិចារណាថាទំនងអាចនឹងកើតឡើង ប្រតិបត្តិករត្រូវកត់ត្រាបញ្ហានេះនៅក្នុងការរាយការណ៍របស់ពួកគេហើយត្រូវផ្តល់នូវករណីសិក្សា។
- ក្នុងករណីដែលបុគ្គលតែមួយនឹងក្លាយជាអ្នកទទួលផលផ្ទាល់ពីកិច្ចការច្រើនដែលទំនងជាត្រូវបានបញ្ចេញនៅក្នុងអំឡុងពេលតែមួយ ហើយនៅពេលដែលចំនួនអ្នកទទួលផលត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចការនីមួយៗអាចនាំឲ្យមានការរាប់ទ្វេដងដែលគួរឲ្យកត់សម្គាល់ វិធីសាស្ត្រកម្រិតជាចង្កោម ឬសហគមន៍ដើម្បីកត់ត្រា និងរាយការណ៍ពីអ្នកទទួលផលអាចត្រូវបានអនុវត្តដើម្បីចៀសវាងការរាប់ទ្វេដង។ ក្នុងករណីទាំងនោះ ចំនួនសរុបនៃអ្នកទទួលផលផ្ទាល់ និងប្រយោលសម្រាប់ចង្កោមកិច្ចការ ឬសហគមន៍គួរត្រូវបានកត់ត្រា ហើយអ្នកទទួលផលទាំងនោះ គួរត្រូវបានរាយការណ៍តែម្តងប៉ុណ្ណោះសម្រាប់កិច្ចសន្យាមួយ។ វាត្រូវបានណែនាំថា ប្រតិបត្តិករបន្តកត់ត្រាទិន្នន័យអ្នកទទួលផលកម្រិតកិច្ចការ បន្ថែមពីលើកម្រិតជាចង្កោមសម្រាប់គោលបំណងចាត់អាទិភាព។
- ក្នុងការរាយការណ៍ទៅម្ចាស់ជំនួយ តួលេខអ្នកទទួលផលគួរត្រូវបានរាយការណ៍នៅក្នុងត្រីមាសទីមួយ/រយៈពេលនៃការរាយការណ៍អំឡុងពេលដែលការងារត្រូវបានធ្វើឡើងដោយក្រុមការងារជាក់លាក់របស់ម្ចាស់ជំនួយស្ថិតក្រោមកិច្ចសន្យា។ ប្រសិនបើមានបរិវេណបន្ថែមត្រូវបានបោសសម្អាតនៅក្នុងសហគមន៍ក្នុងរយៈពេលនៃកិច្ចសន្យា ហើយបានរាយការណ៍នៅក្នុងត្រីមាសក្រោយ វាត្រូវបានទទួលស្គាល់ថាអ្នកទទួលផលផ្ទាល់មួយចំនួនប្រហែលជាត្រូវបានរាប់ថាជាអ្នកទទួលផលប្រយោលពីសហគមន៍រួចហើយនៅក្នុងត្រីមាសមុន។ នៅក្នុងករណីទាំងនោះ ប្រតិបត្តិករត្រូវផ្តល់ដំណឹងដល់ម្ចាស់ជំនួយអំពីការរាប់ទ្វេដែលអាចកើតមាន ហើយប្រសិនបើសមស្របនិងអាចធ្វើទៅបាន ត្រូវកែតម្រូវចំនួនអ្នកទទួលផលរួម។
- ការប្រើប្រាស់បុគ្គលជាក់ស្តែងត្រូវបានលើកទឹកចិត្តក្នុងដោយយកការគណនាចំនួនគ្រួសារគុណនឹងទំហំនៃគ្រួសារមធ្យម។ ក្នុងករណីដែលមិនអាចចៀសវាងបាន ប្រភពសម្រាប់តួលេខគ្រួសារមធ្យមគួរត្រូវបានកត់ត្រា និងព្រមព្រៀងរួមគ្នាជាមួយនឹងអ្នកពាក់ព័ន្ធផ្សេងទៀត នៅក្នុងប្រទេស។[21]

[20] ពាក្យថា «ក្រោយបោសសម្អាត» នៅក្នុងផ្នែកនេះពាក់ព័ន្ធនឹងការរំដោះផ្ទៃដីតាមរយៈការបោសសម្អាត និង ការកាត់បន្ថយ ប៉ុន្តែមិនមែនការលុបចោលទេ។

[21] និយមន័យទាំងនេះទទួលស្គាល់ថាការរាប់សមាជិកគ្រួសារជាអ្នកទទួលផលផ្ទាល់អាចមានការលំបាកនៅក្នុងបរិបទនៃការប្រើប្រាស់ដីជាក់លាក់មួយចំនួន ឧ. អ្នកទទួលផលផ្ទាល់ពីការប្រើប្រាស់ដី សាលារៀន មន្ទីរពេទ្យ និងសេវាសាធារណៈផ្សេងទៀត។ ប្រតិបត្តិករត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ពួកគេនៅពេលដាក់បញ្ចូលសមាជិកគ្រួសារនៅក្នុងបរិបទទាំងនេះ ខណៈពេលដែលប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះដើម្បីរក្សានូវនិយមន័យដែលមានភាពប្រាកដនិយមតាមដែលអាចធ្វើទៅបានដើម្បីចៀសវាងតួលេខត្រូវបានបំប៉ោង។



**រូបភាពខាងលើ៖** ក្មេងៗពីសាលាសាបឋមសិក្សា Santa Helena កំពុងជិះសេះរបស់ពួកគេនៅពេលព្រឹក។ កុមារទាំងនេះអ្នកខ្លះមកពីទីដែលត្រូវចំណាយពេលធ្វើដំណើរពីរម៉ោង។ Santa Helena តំបន់ Meta ប្រទេសកូឡុំប៊ី © Giovanni Diffidenti/អង្គការ NPA

- ក្នុងករណីដែលគ្រួសារច្រើនស្នាក់នៅក្នុងលំនៅដ្ឋានតែមួយ ប្រតិបត្តិករគួរកំណត់សមាជិកគ្រួសារថាជា "បុគ្គលដែលរស់នៅជាមួយគ្នាដែលមានរបបអាហារ និងរបស់របររស់នៅចាំបាច់ផ្សេងទៀតរួមគ្នា។[22] បន្ថែមពីនេះ ដើម្បីការពារពីការបំប៉ោងតួលេខអ្នកទទួលផលផ្ទាល់ហួសកម្រិត ប្រតិបត្តិករគួរកំណត់វិសាលភាពនៃគ្រួសារថាជាអ្នកទាំងឡាយណាដែលរស់នៅជាប្រចាំ ឬទៀងទាត់នៅក្នុងលំនៅដ្ឋានតែមួយ និងមិនត្រូវរាប់បញ្ចូលសមាជិកគ្រួសារច្រើនជំនាន់ដែលរស់នៅទីតាំងផ្សេងគ្នាទេ (លើកលែងតែពួកគេក៏ត្រូវបានកំណត់ផងដែរថាជាអ្នកប្រើប្រាស់/នឹងប្រើប្រាស់ដីដែលបានបោសសម្អាត និងដែលបានកាត់បន្ថយក្រោយបោសសម្អាត)។
- បរិបទគ្រាប់បែកចង្កោមបានបង្ហាញពីផលលំបាកនៅពេលដែលយើងមានគោលបំណងចង់រាប់អ្នកទទួលផលមុនពេលបោសសម្អាត ដោយសារតែទំហំពហុកោណនៃកិច្ចការ (ឬទំហំបរិវេណ) តែងតែមានការកើនឡើងអំឡុងពេលបោសសម្អាត ដោយសារការការខូចរូបរាង។ នៅក្នុងស្ថានភាពទាំងនេះ ប្រតិបត្តិករត្រូវ៖ ក) ផ្តោតលើការកំណត់តំបន់គ្រោះថ្នាក់ឲ្យបានលម្អិតតាមដែលអាចធ្វើទៅបាននៅក្នុងអំឡុងពេលស្រាវជ្រាវមុនពេលការបោសសម្អាតពេញលេញ និង ខ) នៅពេលមិនអាចចៀសវាងការផ្លាស់ប្តូរការរាប់អ្នកទទួលផលផ្ទាល់បាន ត្រូវផ្តល់ដំណឹងដល់អ្នកពាក់ព័ន្ធពីការឡើងចុះនៅក្នុងរបាយការណ៍អ្នកទទួលផលពីពេលមុន។

[22] និយមន័យនេះត្រូវបានយកពីនាយកដ្ឋានស្ថិតិ UN: http://unstats.un.org/unsd/demographic-social/sconcerns/family/#docs

## ប្រភេទនៃការប្រើប្រាស់ដី

- នៅក្នុងអំឡុងពេលនៃការវាយតម្លៃមុនបោសសម្អាត ប្រតិបត្តិករមិនត្រូវបានលើកទឹកចិត្តឲ្យទាមទារប្រភេទនៃការប្រើប្រាស់ដីចម្បងតែមួយសម្រាប់តំបន់ដែលបានធ្វើការស្រាវជ្រាវសម្រាប់កិច្ចការនោះទេ (លើកលែងតែថាជាក់ស្តែងការប្រើប្រាស់ដីដែលបានស្មានទុកមានតែមួយប្រភេទ) ដោយការធ្វើបែបនេះ អាចធ្វើឲ្យជះឥទ្ធិពលដែលមិនត្រឹមត្រូវដល់ដំណើរការចាត់អាទិភាពការបោសសម្អាត។
- ប្រសិនបើអំឡុងពេលនៃការវាយតម្លៃមុនបោសសម្អាត ប្រសិនបើត្រូវបានរកឃើញថាមានប្រភេទនៃការប្រើប្រាស់ដីដែលបានស្មានទុកច្រើនក្នុងកិច្ចការតែមួយត្រូវបានរកឃើញ ការអនុវត្តល្អបំផុតគឺណែនាំដល់ប្រតិបត្តិករឲ្យកត់ត្រាការបែងចែកនេះជាភាគរយដែលបូកបញ្ចូលគ្នាបាន ១០០%។ ភាគរយនេះបន្ទាប់មកអាចបម្លែងទៅជាផ្ទៃដីនៅពេលដែលចាំបាច់។

## អ្នកទទួលផលប្រយោល

- អង្គភាពរដ្ឋបាលតូចបំផុតដែលបានប្រើប្រាស់នៅក្នុងប្រទេសដើម្បីរាប់អ្នកទទួលផលប្រយោលគួរមានការព្រមព្រៀងពីអ្នកពាក់ព័ន្ធទាំងអស់។ អង្គភាពនេះក៏គួរត្រូវបានប្រើនៅក្នុង IMSMA ឬ មូលដ្ឋានទិន្នន័យដែលស្រដៀងគ្នាផ្សេងទៀតនៅក្នុងប្រទេស។
- នៅពេលដែលមិនមានទិន្នន័យប្រជាជនដែលត្រឹមត្រូវ ឬដែលអាចជឿជាក់បានសម្រាប់ការគណនាអ្នកទទួលផលប្រយោល ឬនៅពេលដែលអង្គភាពរដ្ឋបាលមិនអាចធ្វើការកំណត់បានដោយងាយស្រួល ឬចាត់ទុកថាវាមានទំហំធំមិនសមហេតុផលសម្រាប់វិធីសាស្រ្តនេះ កម្មវិធីត្រូវធ្វើការជាមួយអ្នកគ្រប់គ្រងអង្គភាពពាក់ព័ន្ធដើម្បីស្វែងរកការណែនាំពីអាជ្ញាធរមូលដ្ឋានដើម្បីធ្វើការកំណត់វិធីសាស្រ្តដែលត្រឹមត្រូវជាងនេះក្នុងការវាស់វែងអ្នកទទួលផលប្រយោលនៅក្នុងបរិបទនោះ។
- នៅពេលដែលមានចំនួនដែលគួរឲ្យកត់សម្គាល់នៃអ្នកទទួលផលផ្ទាល់ត្រូវបានកំណត់ថារស់នៅក្រៅអង្គភាពរដ្ឋបាលតូចបំផុតដែលនៅជិតបំផុត វាអាចមានហានិភ័យដែលថាចំនួនអ្នកទទួលផលប្រយោលដែលបានគណនារួចហើយនោះអាចធ្លាក់ក្រោមសូន្យ។ នោះជាករណីពិសេសនៅក្នុងតំបន់ទីក្រុងមួយចំនួន ឬនៅកន្លែងដែលការប្រើប្រាស់ដីដែលបានស្មានទុកគឺសម្រាប់សេវាកម្មសហគមន៍/សាធារណៈ។ នៅក្នុងកាលៈទេសៈបែបនេះ ការអនុវត្តល្អបំផុតណែនាំប្រតិបត្តិករឲ្យ ក) កំណត់ការរាប់អ្នកទទួលផលប្រយោលទៅចំនួនដើមគឺសូន្យ (ដើម្បីកុំឲ្យបង្កើតជាលេខអវិជ្ជមាន) ឬ ខ)ប្រសិនបើអាច បែងចែកដាច់ពីគ្នាតើនរណាខ្លះក្នុងចំណោមអ្នកទទួលផលផ្ទាល់ដែលរស់នៅក្រៅអង្គភាពរដ្ឋបាលតូចបំផុត និងបន្ទាប់មកបំបែកក្រុមដែលបានជ្រើសរើសនេះចេញពីការគណនាអ្នកទទួលផលប្រយោល។
- នៅពេលដែលដីដែលបានបោសសម្អាត ឬដីដែលបានកាត់បន្ថយស្ថិតនៅក្នុង ឬនៅចន្លោះទីកន្លែងពីរឬច្រើន អ្នកទទួលផលប្រយោលអាចត្រូវបានរាប់ដោយប្រើប្រាស់ចំនួនប្រជាជននៃអង្គភាពរដ្ឋបាលតូចបំផុតទាំងពីរ/ទាំងអស់ដែលរងផលប៉ះពាល់ (ដកអ្នកទទួលផលផ្ទាល់) អោយតែអង្គភាពរដ្ឋបាលតូចបំផុតទាំងពីរ/ទាំងអស់អាចចូលទៅប្រើប្រាស់តំបន់នោះជាក់ស្តែង (ឧ. ការចូលប្រើប្រាស់មិនត្រូវបានរារាំងដោយសារតែរយៈចម្ងាយ ឬឧបសគ្គធម្មជាតិ)។
- អ្នកពាក់ព័ន្ធដែលធ្វើការនៅក្នុងប្រទេសតែមួយគួរមានការព្រមព្រៀងគ្នាទៅលើចំណុចមួយនៅពេលវេលាណាមួយដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យចំនួនប្រជាជន ជាធម្មតាម្តងក្នុងមួយឆ្នាំ ប៉ុន្តែវាអាចអាស្រ័យលើភាពទៀងទាត់នៃទិន្នន័យជំរឿន។

## ការពិចារណាបន្ថែម

- កម្មវិធីអាចជ្រើសរើសកែប្រែនិយមន័យឲ្យកាន់តែប្រសើរនៅក្នុងបរិបទនៃប្រទេសរបស់ខ្លួន ប៉ុន្តែនិយមន័យរបស់កម្មវិធីត្រូវប្រកាន់ខ្ជាប់យ៉ាងទូលំទូលាយទៅនឹងនិយមន័យសកលដែលបានផ្តល់នៅទំព័រ ១៣ និងត្រូវគិតពិចារណាអំពីស្តង់ដារ ឬគោលការណ៍ណែនាំជាតិណាមួយសម្រាប់និយមន័យអ្នកទទួលផល។ និយមន័យជាក់លាក់សម្រាប់កម្មវិធីណាមួយគួរត្រូវធ្វើឡើងដោយមានការប្រឹក្សាជាមួយអ្នកគ្រប់គ្រងអង្គភាពដែលពាក់ព័ន្ធ និងត្រូវបានសម្របសម្រួលរវាងប្រតិបត្តិករក្នុងប្រទេសដើម្បីធានាភាពស៊ីសង្វាក់គ្នាសម្រាប់កម្មវិធីរបស់អង្គភាពទាំងអស់ និងក្នុងចំណោមប្រតិបត្តិករផងដែរ។
- វាមានករណីខ្លះដែលសកម្មភាពរំដោះផ្ទៃដីត្រូវបានអនុវត្តច្រើនដងទៅលើតំបន់មួយដែលត្រូវបានផ្តល់ឲ្យ។ ឧទាហរណ៍ ការស្រាវជ្រាវផ្ទៃខាងក្រោម អាចត្រូវបានធ្វើឡើងបន្ទាប់ពីការស្រាវជ្រាវផ្ទៃខាងលើ បន្ទាប់ពីពេលវេលាណាមួយ ហើយត្រូវផ្អែកលើលក្ខខណ្ឌតម្រូវនៃការប្រើប្រាស់ដី។ ក្នុងករណីនេះ ការរាប់អ្នកទទួលផលអាចត្រូវបានផ្លាស់ប្តូរ ប៉ុន្តែមិនត្រូវបានគិតជាន់គ្នានោះទេ។
- ការដាក់សញ្ញាសម្គាល់យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងតំបន់គ្រោះថ្នាក់រួមមាន ការដាក់របង ត្រូវបានធ្វើឡើងដោយប្រតិបត្តិករ។ ការដាក់សញ្ញាសម្គាល់អាចជាសកម្មភាពជួយសង្គ្រោះជីវិត ការពារមនុស្សពីការចូលទៅតំបន់គ្រោះថ្នាក់សម្រាប់រយៈពេលវែងរហូតដល់ពេលដែលការបោសសម្អាត ឬ EOD អាចធ្វើទៅបាន។ ការគណនាអ្នកទទួលផលពីការដាក់សញ្ញាសម្គាល់មិនមានរួមបញ្ចូលនៅក្នុងឯកសារនេះទេ។

- នៅពេលរាយការណ៍អ្នកទទួលផលសម្រាប់ដីដែលបានលុបចោល (សូមមើលខាងលើសម្រាប់ស្ថានភាពជាក់លាក់) ពួកគេគួរត្រូវបានរាយការណ៍ដាច់ដោយឡែកពីអ្នកទទួលផលនៃដីដែលបានសម្អាត ឬដីដែលបានកាត់បន្ថយ។

# កិច្ចជួយសង្គ្រោះជនរងគ្រោះ

## ការកំណត់អ្នកទទួលផល

អ្នកទទួលផលផ្ទាល់ពីកិច្ចជួយសង្គ្រោះជនរងគ្រោះ (VA) ត្រូវបានកំណត់ថាជាជនរងគ្រោះ[23] ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (EO) ដែលត្រូវបានបញ្ជូនទៅ ឬទទួល សេវាកម្មនៅក្នុងវិស័យដែល VA គឺជាផ្នែកមួយ ដូចដែលបានរៀបរាប់សង្ខេបនៅក្នុងប្រអប់ខាងក្រោម។

> កិច្ចជួយសង្គ្រោះជនរងគ្រោះជាផ្នែកមួយនៃវិស័យដូចតទៅនេះ៖ ការថែទាំងវេជ្ជសាស្ត្រជាបន្ទាន់និងបន្ត ការស្តារនិតិសម្បទា រួមទាំងការផ្តល់អវយវៈសិប្បនិម្មិតនិងរណប ការគាំទ្រសុខភាពផ្លូវចិត្តនិងចិត្តសាស្ត្រសង្គម និងបរិយាប័ន្នសេដ្ឋកិច្ចសង្គម ឧ. បរិយាប័ន្នការអប់រំ ការធ្វើការឲ្យខ្លួនឯង ឬការធ្វើការដោយទទួលប្រាក់ឈ្នួល ក៏ដូចជាបរិយាប័ន្នកីឡា សកម្មភាពកម្សាន្ត និងវប្បធម៌។

អ្នកទទួលផលផ្ទាល់អាចរួមបញ្ចូលបុគ្គលផ្សេងទៀតដែលមានតម្រូវការដូចគ្នា ទៅតាមគោលការណ៍នៃការមិនរើសអើងដែលបង្ហាញផ្លូវដល់ VA។ អ្នកទទួលផលប្រយោលនៃកិច្ចជួយសង្គ្រោះជនរងគ្រោះរួមមានពីរក្រុម៖

- បុគ្គលដែលត្រូវបានកំណត់ទៅតាម IMAS 13.10[24] និង ដែលព័ត៌មានរបស់ពួកគេត្រូវបានចែករំលែកជាមួយ នឹងអង្គភាពដែលផ្តល់សេវានៅក្នុងវិស័យដែល VA ជាផ្នែកមួយនៃវិស័យនោះ។
- បុគ្គលដែលរស់នៅក្នុងគ្រួសារតែមួយជាមួយអ្នកទទួលផលផ្ទាល់។

[23] IMAS 13.10 ឲ្យនិយមន័យ “ជនរងគ្រោះ” ថាជា “បុគ្គល មិនថាជាខ្លួនឯងផ្ទាល់ ឬជាក្រុមដែលរងគ្រោះផ្លូវកាយ អារម្មណ៍ និងផ្លូវចិត្ត បាត់បង់ផ្នែកសេដ្ឋកិច្ច ឬការអន់ថយជាខ្លាំងនៃសិទ្ធិជាមូលដ្ឋានរបស់ពួកគេដោយសារតែសកម្មភាព ឬការខកខានដែលពាក់ព័ន្ធនឹងការប្រើប្រាស់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (EO)។” ជនរងគ្រោះរួមបញ្ចូលទាំងបុគ្គលដែលរងរបួស និងបាត់បង់ជីវិត ក្រុមគ្រួសាររបស់ពួកគេ និងសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយ EO។ ពាក្យ “អ្នកនៅរស់” ត្រូវបានប្រើទាក់ទងនឹងស្ត្រី កុមារី កុមារា និងបុរសទាំងឡាយណាដែលបានរងរបួសហើយតែនៅរស់រានមានជីវិត តែអាចនឹងចុះខ្សោយសមត្ថភាពដោយបណ្តាលមកពីគ្រោះថ្នាក់ដោយសារ EO។

[24] IMAS 13.10 តម្រូវឲ្យប្រតិបត្តិករសកម្មភាពកម្ចាត់មីនទាំងអស់ចែករំលែកទិន្នន័យ និងចំណេះដឹងអំពីភាពចាំបាច់នៃការកំណត់ជនរងគ្រោះ និងបុគ្គលផ្សេងទៀតដែលមានតម្រូវការស្រដៀងគ្នាជាមួយនឹងអង្គភាពជាតិដែលសមស្រប។ ការចែករំលែកទិន្នន័យជាមួយនឹងប្រតិបត្តិករផ្សេងៗនៅក្នុងវិស័យដែល VA ជាផ្នែកមួយនៃវិស័យនោះ គឺដើម្បីចូលរួមឲ្យកាន់តែទូលំទូលាយនៅក្នុងការគាំទ្រពហុវិស័យ ហើយម្ចាស់ជំនួយក៏ត្រូវបានណែនាំឲ្យធ្វើបែបនេះផងដែរ។ ការធ្វើបែបនេះអាចត្រូវប្រើប្រាស់ទម្រង់ជាដៃគូក្រៅផ្លូវការ និងការចែករំលែកព័ត៌មានទូទៅ ជាជាងការបញ្ជូនបុគ្គលទៅកាន់អ្នកផ្តល់សេវា - ដែលប្រតិបត្តិករសកម្មភាពកម្ចាត់មីនមិនមានវិធីដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ថាតើមានការផ្តល់សេវាកម្មជាបន្តបន្ទាប់ ឬថាការចូលទៅប្រើប្រាស់សេវារបស់បុគ្គលត្រូវបានសម្របសម្រួលដែរឬទេ ហើយហេតុដូច្នេះ បុគ្គលដែលទទួលបានប្រយោជន៍ពីសកម្មភាពទាំងនេះត្រូវបានមើលឃើញថាជាអ្នកទទួលផលប្រយោលរបស់ VA។

***រូបភាពខាងក្រោម៖*** បុរសម្នាក់នេះនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន ដែលរងរបួសនៅក្នុងគ្រោះថ្នាក់ដោយសារមីន បានទទួលសេវាកម្មស្តារនិតិសម្បទា និងការព្យាបាលសាច់ដុំចុះខ្សោយ។ ©Jaweed Tanveer/អង្គការ HI



## គោលការណ៍ណែនាំស្តីពីការវាស់វែង និងការរាយការណ៍ពីអ្នកទទួលផល VA

- ប្រតិបត្តិករសកម្មភាពកម្ចាត់មីនដើរតួនាទីសំខាន់ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយសារ EO។ យោងតាម IMAS 13.10 វិស័យសកម្មភាពកម្ចាត់មីន ត្រូវចូលរួមចំណែកនៅកម្រិតអប្បបរមាក្នុងការជួយសម្រួលដល់ការទទួលបានសេវាកម្មសម្រាប់ជនរងគ្រោះដែលបានកំណត់ និងបុគ្គលផ្សេងទៀតដែលមានតម្រូវការស្រដៀងគ្នា តាមរយៈកិច្ចខិតខំប្រឹងប្រែងជាក់លាក់ដែលជាផ្នែកមួយនៃ NTS, EORE, ការបោសសម្អាត ការតស៊ូមតិ និងសកម្មភាពផ្សេងៗជាទៀងទាត់របស់ខ្លួន។ វិស័យនេះអាចបន្តទៅមុខទៀត ហើយក៏នឹងផ្តល់សេវាដោយផ្ទាល់នៅក្នុងវិស័យសុខាភិបាល ការស្តារនិតិសម្បទា ការគាំទ្រសុខភាពផ្លូវចិត្តនិងចិត្តសាស្ត្រសង្គម ការអប់រំ ការចិញ្ចឹមជីវិត និងបរិយាប័ន្នសង្គម។
- អ្នកទទួលផលផ្ទាល់នៃកិច្ចខិតខំប្រឹងប្រែងដែលមានគោលបំណងក្នុងការសម្របសម្រួលដើម្បីទទួលបានសេវាវេជ្ជសាស្ត្រ និងសេវាផ្សេងទៀតនៅក្នុងវិស័យដែល VA ជាផ្នែកមួយ គួរត្រូវបានរាប់ថាជាចំនួនបុគ្គលដែល៖
  - ◊ មានស្ថានភាពគ្រោះថ្នាក់ដល់អាយុជីវិត ហើយត្រូវបានផ្តល់ជូនការដឹកជញ្ជូនវេជ្ជសាស្ត្របន្ទាន់
  - ◊ មានស្ថានភាពគ្រោះថ្នាក់មិនដល់ជីវិតហើយអាចទទួលសេវាកម្មវេជ្ជសាស្ត្រដែលសម្របសម្រួលតាមរយៈការផ្តល់ជូននូវការធ្វើដំណើរ ឬថវិកា
  - ◊ បានបញ្ជូនទៅកាន់សេវាពាក់ព័ន្ធផ្សេងទៀតនៅក្នុងវិស័យដែល VA ជាផ្នែកមួយ
- ប្រសិនបើប្រតិបត្តិករសកម្មភាពកម្ចាត់មីនបានចូលរួមក្នុងការផ្តល់សេវាដោយផ្ទាល់នៅក្នុងវិស័យដែល VA ជាផ្នែកមួយ អ្នកទទួលផលផ្ទាល់នៃសេវាទាំងនេះគួរត្រូវបានរាប់ថាជាចំនួនបុគ្គលដែលបានទទួល៖
  - ◊ ការគ្រប់គ្រងករណី រួមបញ្ចូលទាំងតាមរយៈដំណើរការនៃការបញ្ជូនបន្ត

◊ សេវាវេជ្ជសាស្ត្របន្ទាន់ និងកំពុងបន្ត



◊ ការគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសាស្ត្រសង្គម

◊ ការព្យាបាលដោយចលនា

◊ សេវាអវយវៈសិប្បនិម្មិត និងរណប និងឧបករណ៍ជំនួយផ្សេងទៀត និងបច្ចេកវិទ្យា[25] រួមទាំងជំនួយក្នុងការធ្វើចលនាដូចជា រទេះរុញ និងឈើច្រត់ ក៏ដូចជាជំនួយក្នុងការស្ដាប់ ការមើលឃើញ និងជំនួយផ្សេងៗទៀត

◊ ការគាំទ្រដោយការដាក់បញ្ចូលសេដ្ឋកិច្ចសង្គម។

- អ្នកទទួលផលផ្ទាល់អាចបានទទួលប្រយោជន៍ពីកិច្ចខិតខំប្រឹងប្រែងជាក់លាក់ជាច្រើនព្រោះតែសកម្មភាពទាំងនេះមានការចូលរួមពីបុគ្គលិកផ្សេងៗគ្នា និងមានលទ្ធផលដែលរំពឹងទុកខុសៗគ្នាផងដែរ។ វាត្រូវបានណែនាំឲ្យរាប់ចំនួនអ្នកទទួលផលផ្ទាល់សរុបតែម្ដង ទោះបីជាពួកគេទទួលប្រយោជន៍ពីកិច្ចខិតខំប្រឹងប្រែងច្រើនក៏ដោយ ហើយត្រូវរាយការណ៍ចំនួនបុគ្គលដែលបានទទួលប្រភេទសេវាកម្មនីមួយៗដាច់ដោយឡែកពីគ្នា។
- អ្នកទទួលផលប្រយោលគួរត្រូវបានរាប់ថាជាអ្នកដែល៖

◊ ត្រូវបានកំណត់តាម IMAS 13.10 និង ដែលព័ត៌មានអំពីការរងរបួស និងតម្រូវការរបស់ពួកគេត្រូវបានផ្សព្វផ្សាយទៅវិស័យដទៃដែលទទួលខុសត្រូវក្នុងការធានាការទទួលបាន និងការផ្ដល់សេវា (ឧ. ការថែទាំវេជ្ជសាស្ត្របន្ទាន់និងបន្ត ការស្ដារនិតិសម្បទា រួមទាំងអវយវៈសិប្បនិម្មិតនិងរណប ការគាំទ្រសុខភាពផ្លូវចិត្តនិងចិត្តសាស្ត្រសង្គម ការអប់រំប្រកបដោយបរិយាប័ន្ន ការធ្វើការឲ្យខ្លួនឯងឬធ្វើការបានប្រាក់ឈ្នួល កីឡាប្រកបដោយបរិយាប័ន្ន សកម្មភាពកម្សាន្ត និងវប្បធម៌)។

◊ ឬរស់នៅក្នុងគ្រួសារតែមួយជាមួយអ្នកទទួលផលផ្ទាល់ (នៅពេលដែលបានទទួលសេវា)[26]។

---

[25] http:/www.who.int/disabilities/technology/en/

[26] ឧទាហរណ៍ បុគ្គលដែលបានទទួលឧបករណ៍អវយវៈសិប្បនិម្មិត គឺជាអ្នកទទួលផលផ្ទាល់ ហើយសមាជិកក្រុមគ្រួសារផ្សេងទៀតគឺជាអ្នកទទួលផលប្រយោលព្រោះពួកគេទទួលប្រយោជន៍មិនផ្ទាល់។ ឬកូនរបស់ឪពុកម្ដាយដែលបានស្លាប់ដោយការផ្ទុះយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទទួលបានការគាំទ្រឲ្យនៅបន្តការសិក្សា - ក្មេងទាំងនេះជាអ្នកទទួលផលផ្ទាល់ ហើយក្រុមគ្រួសារដែលនៅសល់ជាអ្នកទទួលផលប្រយោល។









**រូបភាពខាងលើ (តាមទ្រនិចនាឡិកាពីខាងឆ្វេងផ្នែកខាងលើ)៖** អ្នកភូមិនៅក្នុងភូមិ Nonsomboum ប្រទេសឡាវ កំពុងប្រកបាវខ្សាច់ដែលជាផ្នែកមួយនៃតម្រូវការការងារការពារនៅពេលដែលគេរកឃើញគ្រាប់ទម្លាក់ពីយន្តហោះនៅជាយភូមិរបស់ពួកគេ។ ការកម្ទេចគ្រាប់នេះបានយកចេញនូវគ្រោះថ្នាក់ដ៏ធំមួយរបស់អ្នកភូមិ ដែលពេលនេះពួកគេអាចចូលរួមក្នុងសកម្មភាពប្រចាំថ្ងៃដោយគ្មានការភ័យខ្លាច។ ©អង្គការ HALO Trust

# ការកម្ទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

## ការកំណត់អ្នកទទួលផល

ទោះបីជាដំណើរការនៃការកម្ទេចគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (EOD)[27] និងការរំដោះផ្ទៃដីមើលទៅដូចជាស្រដៀងគ្នា តែអ្នកទទួលផលនៃសកម្មភាពទាំងពីរនេះទទួលបានអត្ថប្រយោជន៍តាមវិធីផ្សេងគ្នា។ ដូច្នេះវាសំខាន់ណាស់ដែលមិនត្រូវចាត់ទុកថាអ្នកទទួលផលនៃសកម្មភាពទាំងពីរនេះត្រូវតែមានៅភាពស្មើគ្នាទេ។ អត្ថប្រយោជន៍នៃសកម្មភាពទាំងពីរមិនមានតម្លៃស្មើគ្នានោះទេសម្រាប់ស្ត្រី កុមារី កុមារា និងបុរសម្នាក់ៗដែលបានរងផលប៉ះពាល់ដោយសារវត្តមាននៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (EO)។ ក្នុងករណីការរំដោះផ្ទៃដី ពួកគេបានទទួលផលពីបរិវេណដែលមិនមានភស្តុតាងនៃការបន្សល់ទុកនូវ EO នៅពេលដែលប្រគល់ទៅឲ្យពួកគេ ខណៈពេលដែលករណី EOD អត្ថប្រយោជន៍គឺជាទម្រង់នៃហានិភ័យដែលបានកាត់បន្ថយ ប៉ុន្តែមិនមានការធានាថាមិនមានគំរាមកំហែងពីការផ្ទុះផ្សេងទៀតដែលនៅសេសសល់ហើយនៅតែអាចបង្កឲ្យមានគ្រោះថ្នាក់ឡើយ។

**អ្នកទទួលផលផ្ទាល់នៃការងារអន្តរាគមន៍** EOD ត្រូវបានកំណត់ថាជាបុគ្គលដែលមានហានិភ័យគ្រោះថ្នាក់ដល់ជីវិតរបស់ពួកគេ ដោយរងរបួស ឬរងការខូចខាតធ្ងន់ធ្ងរដល់ការកាត់បន្ថយធនធានដែលបណ្តាលមកពីកាតព្វកិច្ច ក្នុងនោះរួមទាំងសមាជិកគ្រួសារផ្ទាល់របស់ពួកគេ និងបុគ្គលទាំងឡាយណាដែលត្រូវបានរារាំងពីការប្រើប្រាស់ធនធានរូបវ័ន្តដោយសារវត្តមានរបស់ EO និងការគំរាមកំហែងដែលបង្កឡើង ទាំងជាការពិត ឬជាការយល់ឃើញ។

**អ្នកទទួលផលប្រយោល** ត្រូវបានកំណត់ថាជាសមាជិកគ្រួសាររបស់អ្នកទទួលផលផ្ទាល់ទាំងឡាយដែលត្រូវបានរារាំងពីការប្រើប្រាស់ធនធានរូបវ័ន្តដោយសារវត្តមានរបស់ EO និងអ្នកដទៃទៀតដែលបានជម្លៀសចេញដើម្បីអនុវត្តការងារ EOD ដោយសុវត្ថិភាព។

[27] សូមមើល IMAS 09.30



**រូបភាពខាងលើ៖** ក្រុមការងារ EOD កំពុងត្រួតពិនិត្យគ្រាប់កាំភ្លើងបេបាញ់គ្រាប់រ៉ុកកែត និងគ្រាប់កាំភ្លើងត្បាល់ដែលអ្នកទទួលផលជាជនជាតិកម្ពុជា និងប្ដីរបស់គាត់បានរកឃើញនៅក្នុងដីរបស់ពួកគេ មុនពេលដែលវាត្រូវបានយកចេញទៅកម្ទេចនៅកន្លែងផ្សេង ។ ©Sean Sutton/អង្គការ MAG

## គោលការណ៍ណែនាំទៅលើការវាស់វែង និងការរាយការណ៍ពីអ្នកទទួលផល EOD

- ការរាប់អ្នកទទួលផល EOD គួរត្រូវបានធ្វើឡើងដោយប្រើប្រាស់ដំណើរការបីជំហាន៖
  ១. បុគ្គលដែលបានរាយការណ៍ពីគ្រាប់ EOD និងសមាជិកគ្រួសាររបស់ពួកគាត់គឺជាអ្នកទទួលផល*ផ្ទាល់*។
  ២. អ្នកប្រើប្រាស់ទូទៅណាម្នាក់នៃធនធានរូបវន្តដែលត្រូវបានរារាំងពីការប្រើប្រាស់ធនធាននោះដោយសារវត្តមានរបស់ EO និងការគំរាមកំហែងដែលបង្កឡើង ទាំងជាការពិត ឬជាការយល់ឃើញ គឺជាអ្នកទទួលផល*ផ្ទាល់* (ឧ. កុមារ និងគ្រូបង្រៀនមិនអាចទៅសាលាបានដោយសារតែរកឃើញថាមាន EO នៅក្នុងថ្នាក់រៀន)។
  ៣. សមាជិកគ្រួសាររបស់អ្នកទទួលផលផ្ទាល់ដែលបានកំណត់នៅក្នុងជំហានទី ២ ខាងលើ ហើយបន្ថែមពីលើនេះគឺបុគ្គលផ្សេងទៀតណាម្នាក់ដែលអាចតម្រូវឲ្យជម្លៀសចេញដើម្បីអនុវត្តការងារ EOD គឺជាអ្នកទទួលផល*ផ្ទាល់*។
- វាត្រូវបានគេរំពឹងទុកថាបុគ្គលមួយចំនួននឹងទទួលបានអត្ថប្រយោជន៍ពីការងារអន្តរាគមន៍ EOD លើសពីមួយដង។ ដោយអនុលោមតាមគោលការណ៍ «កិច្ចខិតខំប្រឹងប្រែងសមស្រប» យើងមិនចាំបាច់ព្យាយាមរាប់អ្នកទទួលផលពិសេសដាក់លាក់ក្នុងការងារអន្តរាគមន៍ឡើយ។ ប្រសិនបើការរាប់ចំនួនអ្នកទទួលផល EOD កើនដល់ចំនួនប្រជាជនសរុបនៃអង្គភាពរដ្ឋបាលតូចបំផុតមុនពេលដែលការងារអន្តរាគមន៍ EOD ទាំងអស់នៅក្នុងតំបន់នោះត្រូវបានអនុវត្ត ប្រតិបត្តិករអាចបន្តរាយការណ៍ពីអ្នកទទួលផល EOD ទៅកាន់ម្ចាស់ជំនួយដោយការអត្ថាធិប្បាយជាមួយនឹងការបញ្ជាក់ថា៖
  ក) តួលេខអ្នកទទួលផលបន្ថែមនេះមិនត្រូវបានបន្ថែមទៅក្នុងចំនួនអ្នកទទួលផលសរុបដែលបានរាយការណ៍សម្រាប់តំបន់នោះទេ និង
  ខ) នេះជាការផ្ដល់ព័ត៌មានយ៉ាងសមស្របទៅកាន់ម្ចាស់ជំនួយ។
- សម្រាប់គោលបំណងស្ថិតិផ្ទៃក្នុង រាយការណ៍ជាប្រចាំឆ្នាំ មិនមានអង្គភាពណាមួយត្រូវរាយការណ៍ចំនួនអ្នកទទួលផលដែលលើសពីចំនួនប្រជាជនសរុបនៃអង្គភាពរដ្ឋបាលដែលតូចបំផុតឡើយ។
- អ្នកពាក់ព័ន្ធដែលធ្វើការនៅក្នុងប្រទេសតែមួយត្រូវព្រមព្រៀងទៅលើចំនុចមួយនៅពេលវេលាណាមួយដើម្បីធ្វើបច្ចុប្បន្នភាពលើទិន្នន័យនៃ

ចំនួនប្រជាជន ដោយជាទូទៅម្តងក្នុងមួយឆ្នាំ ប៉ុន្តែការធ្វើបែបនេះអាចអាស្រ័យទៅលើភាពទៀតទាត់នៃទិន្នន័យជំរឿននោះផងដែរ។

- នៅក្នុងតំបន់ទីប្រជុំជន ឬតំបន់ដែលមានប្រជាជនច្រើនកុះករ ចំនួនច្បាស់លាស់នៃប្រជាជនដែលបានជម្លៀសចេញ ឬសមាជិកគ្រួសារដែលរាប់ជាអ្នកទទួលផលប្រយោល ប្រហែលជាមិនអាចធ្វើបានទេ។ នៅក្នុងករណីទាំងនេះ យើងអាចត្រូវធ្វើការប៉ាន់ស្មាន។ ការប៉ាន់ស្មានទាំងនេះអាចត្រូវបានកំណត់ដោយប្រើប្រាស់ដង់ស៊ីតេប្រជាជននៃបរិវេណដែលនៅជុំវិញ[28] ឬតាមរយៈការសម្ភាសន៍ជាមួយអ្នកតំណាងភូមិ។ ប្រភពនៃតួលេខអ្នកទទួលផលប្រយោលគួរត្រូវបានកត់ត្រា និងរាយការណ៍ (ឧ. ការរាប់ចំនួនប្រជាជនដែលបានជម្លៀសចេញជាក់ស្តែង ទិន្នន័យដង់ស៊ីតេប្រជាជន ឬការសម្ភាសន៍អ្នកអោយការណ៍សំខាន់ៗ)។
- អ្នកទទួលផលគួរត្រូវបានកត់ត្រាទៅតាមការងារ មិនមែនទៅតាមចំនួននៃ EO ទេ។ ដូចនេះ ប្រសិនបើការងារមួយមាន EO ច្រើនជាងមួយ កិច្ចខិតខំប្រឹងប្រែងសមហេតុផលគួរត្រូវបានធ្វើឡើងដើម្បីធានាថាអ្នកទទួលផលមិនត្រូវបានរាប់ទ្វេដង។[29]
- នៅក្នុងសេណារីយ៉ូដែលការងារអន្តរាគមន៍ EOD អាចមានសក្តានុពលក្នុងផ្តល់ប្រយោជន៍ដល់ចំនួនមនុស្សច្រើន ការងារនេះគួរត្រូវបានរាយការណ៍ដាច់ដោយឡែកពីគ្នា (ឧ. ជាករណីសិក្សា) ស្រដៀងគ្នានឹងការប្រើប្រាស់ដីហេដ្ឋារចនាសម្ព័ន្ធធំៗដូចដែលបានរៀបរាប់លម្អិតនៅក្នុងនិយមន័យនៃការរំដោះផ្ទៃដីខាងលើ។ នៅក្នុងករណីទាំងនេះ ត្រូវតែច្បាស់ថាតួលេខអ្នកទទួលផលដែលបានដកស្រង់បានមកដោយរបៀបណា។
- ទោះបីជាការងារ EOD មិនបាននាំឲ្យមានលទ្ធផលរំដោះផ្ទៃដីដោយខ្លួនវាផ្ទាល់ក៏ដោយ ប្រតិបត្តិករអាចនឹងរាយការណ៍ពីលក្ខណៈនៃតំបន់នោះពីការចូលទៅប្រើប្រាស់ត្រូវបានរាំងដោយសារវត្តមាន EO។ ការងារនេះត្រូវធ្វើឡើងដោយប្រភេទដីប្រើប្រាស់ដូចគ្នានឹងការរាយការណ៍អ្នកទទួលផលពីការរំដោះផ្ទៃដីដែលបានរៀបរាប់នៅក្នុងផ្នែកខាងលើ។

**រូបភាពខាងក្រោម៖** កុមារកំពុងតែរត់លេងនៅក្នុងទីធ្លានៃសាលាបឋមសិក្សាមួយនៃ Santa Helena, Meta នៃប្រទេសកូឡុំប៊ី។©Giovanni Diffidenti/អង្គការ NPA



[28] ដើម្បីទទួលបានតួលេខដង់ស៊ីតេប្រជាជន (ចំនួនប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េ ឬមួយម៉ាយល៍ការ៉េ) ចាំបាច់ត្រូវមានទំហំនៃបរិវេណរបស់អង្គភាពរដ្ឋបាលទាំងមូល។ ក្នុងករណីដែលទិន្នន័យទាំងនេះមិនអាចរកបានជាសាធារណៈ បុគ្គលិក GIS ដែលទទួលបានការបណ្តុះបណ្តាលអាចគណនាបរិវេណប្រហាក់ប្រហែលដោយផ្អែកលើព្រំប្រទល់នៃអង្គភាពរដ្ឋបាលតូចបំផុត។ បន្ទាប់មកតួលេខនេះត្រូវប្រើប្រាស់សម្រាប់ការងារអន្តរាគមន៍ EOD ទាំងអស់នៅក្នុងតំបន់ភូមិសាស្ត្រទាំងនេះ។ នៅក្នុងតំបន់ដែលដង់ស៊ីតេប្រជាជនរបស់អង្គភាពរដ្ឋបាលតូចបំផុតមិនសមស្របទៅនឹងស្ថានភាពនៃបញ្ហា ប្រតិបត្តិករអាចសម្របសម្រួលដើម្បីព្រមព្រៀងទៅលើអ្វីដែលអង្គភាពរដ្ឋបាលអាចអនុវត្តបានល្អបំផុត ហើយនឹងត្រូវបានយកទៅប្រើប្រាស់។

[29] អ្នកទទួលផលសម្រាប់ការងារអន្តរាគមន៍ដែលមានជាតុនៃគ្រាប់អាវុធធុនស្រាល (ព្យាស <២០មម) ជាទូទៅមិនគួរត្រូវបានរាប់បញ្ចូលឡើយ។



**រូបភាពខាងលើ៖** នារីវ័យក្មេងនៅក្នុងភូមិ Ngamari ប្រទេសនីហ្សេរីយ៉ា។ © Sean Sutton/អង្គការ MAG

DCA
actalliance

DANISH
DEMINING
GROUP

FSD

THE
HALO
TRUST

humanity
&inclusion

MAG
saves lives builds futures

Norwegian People's Aid